នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Oct-2019, 13:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសំណើរបស់ ខៀវ សំផន សុំឲ្យទទួលយកភស្តុតាងបន្ថែម (F51)

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ

**ជនជាប់ចោទ:**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន:**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## I. សេចក្តីផ្តើម

1. សំណើរបស់ ខៀវ សំផន សុំឲ្យទទួលយកភស្តុតាងបន្ថែម (“សំណើសុំការអនុញ្ញាតឲ្យទទួលយក”) ដែលបានស្វែងរកការអនុញ្ញាតឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយចំនួនពីរ និងកំណត់ត្រាស្តាប់ចម្លើយជាខ្សែអាត់សម្លេងរបស់ពួកគេរៀងៗខ្លួន[1] គួរត្រូវបានបដិសេធចោល ដោយហេតុថា មិនទាន់ពេលវេលា និងមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យហ្មត់ចត់ ក្នុងការទទួលយកភស្តុតាងបន្ថែម ក្នុងអំឡុងពេលនៃដំណាក់ការកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដូចដែលបានពិភាក្សានៅខាងក្រោម។ លក្ខណៈវិនិច្ឆ័យទាំងនេះ គឺចាំបាច់យ៉ាងខ្លាំង ព្រោះថាភស្តុតាងដែលបានស្នើសុំនោះ ត្រូវតែបានវាយតម្លៃក្នុងបរិបទនៃភស្តុតាងដែលបានផ្តល់នៅពេលសវនាការ[2] ហើយអង្គជំនុំជម្រះបណ្តឹងសាទុក្ខត្រូវប្រយ័ត្នក្នុងការពិនិត្យមើលភស្តុតាង *ជាថ្មីម្តងទៀត*[3]។

2. ជាពិសេស សំណើសុំការអនុញ្ញាតឲ្យទទួលយក គឺមិនទាន់ពេលវេលា ដោយហេតុថា ខៀវ សំផន មិនបានប្រើប្រាស់ឱកាសដាក់បង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីលើកឡើងនូវបញ្ហានេះជា

---

[1] ឯកសារ **F51** សំណើរបស់លោក ខៀវ សំផន សុំឲ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ (“សំណើសុំការអនុញ្ញាតឲ្យទទួលយក”)។

[2] *សូមមើល ឧទា. រដ្ឋអាជ្ញា ទល់នឹង* Popović *តួកន* IT-05-88-A អង្គជំនុំជម្រះសាឧទ្ធរណ៍ សេចក្តីសម្រេចលើញត្តិរបស់ Vujadin Popović ស្នើសុំឲ្យទទួលយកភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១១៥ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ ៣៩ (“ភាពសំខាន់ និងផលប៉ះពាល់ជាសក្តានុពលនៃសម្ភារៈដែលបានផ្តល់ជូន ត្រូវតែបានវាយតម្លៃនៅក្នុងបរិបទនៃភស្តុតាងដែលបានដាក់បង្ហាញនៅក្នុងសវនាការ”)។ *រដ្ឋអាជ្ញា ទល់នឹង Simić* IT-95-9-A អង្គជំនុំជម្រះសាឧទ្ធរណ៍ សេចក្តីសម្រេចលើញត្តិរបស់ Blagoje Simić ស្នើសុំឲ្យទទួលយកភស្តុតាងបន្ថែម, ដោយផ្លាស់គ្នាសម្រាប់ការយកសេចក្តី ជូនដំណឹងរបស់តុលាការ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៦ កថាខណ្ឌ ១៤។ *រដ្ឋអាជ្ញា ទល់នឹង Ntakirutimana និង Ntakirutimana* ICTR-96-10-A និង ICTR-96-17-A អង្គជំនុំជម្រះសាឧទ្ធរណ៍ សេចក្តីសម្រេចលើសំណើសុំឲ្យទទួលយក ភស្តុតាងបន្ថែម ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ៥ (“ភស្តុតាងបន្ថែមត្រូវតែបានពិចារណានៅក្នុងបរិបទនៃភស្តុតាង ដែលត្រូវបានផ្តល់ឲ្យនៅពេលសវនាការ ហើយមិនត្រូវនៅដាច់តែឯង”)។

[3] *សូមមើល ឧទា.* ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ (“សាលដីកាលើសំណុំរឿង០០២/០១”) កថាខណ្ឌ ២៩ (“អង្គជំនុំជម្រះតុលាការកំពូលមានតួនាទីក្នុងការផ្ទៀងផ្ទាត់ឲ្យឃើញថា លក្ខខណ្ឌក្នុងការបង្ហាញធាតុផ្សំនៃបទចោទឲ្យហួសពីវិមតិសង្ស័យត្រូវបានបំពេញ ដោយពុំចាំបាច់ធ្វើការវាយតម្លៃ*សារជាថ្មី*លើភស្តុតាងឡើយ”) កថាខណ្ឌ ៩៤។ *រដ្ឋអាជ្ញា ទល់នឹង* *Rutaganda* ICTR-96-3-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ (“សាលដីកា *Rutaganda*”) កថាខណ្ឌ ៥០៥ (“វាជារឿងក្តីដែលដោះស្រាយរួចហើយ ដែលបណ្តឹងឧទ្ធរណ៍មួយមិនត្រូវពិនិត្យ*សារជាថ្មី*។ ដូច្នេះ ដោយផ្អែកលើគោលការណ៍នេះ វាមិនត្រូវធ្លាក់ទៅលើអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែលត្រូវបើកសវនាការ*សារជាថ្មី* នៃដើមបណ្តឹងឧទ្ធរណ៍នោះទេ [...] និង/ឬ កំណត់ថាតើការវាយតម្លៃដែលខុសគ្នាមួយនៃភស្តុតាងបង្ហាញនៅពេលសវនាសការនឹងត្រូវបានរក្សានូវការរកឃើញពីពិរុទ្ធភាពដែរ ឬយ៉ាងណា”)។

មួយខ្លួន មុននឹងខ្លួនឈានដល់សាលក្រមនៅក្នុងសំណុំរឿងនេះ។ បន្ថែមលើនេះ គាត់ខកខានមិនបានបកស្រាយបង្ហាញទៅតាមលក្ខណៈវិនិច្ឆ័យនៃការទទួលយកនៃវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ដែលថាកំណត់ហេតុស្តាប់ចម្លើយអាចជាកត្តាសម្រេចមួយនៅក្នុងសេចក្តី សម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[4]។ ថែមទាំងមិនមានផលប្រយោជន៍នៃយុត្តិធម៌ ស្របតាមវិធាន១០៤(១) នៃវិធានផ្ទៃក្នុង ដែលតម្រូវឲ្យមានការទទួលយករបស់ពួកគាត់[5]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) បដិសេធចោលនូវសំណើសុំការអនុញ្ញាតឲ្យទទួលយកនេះ។

3. ចម្លើយតបនេះនឹងមិនលើកឡើងពីអំណះអំណាងរបស់ ខៀវ សំផន ដែលហួសពីវិសាលភាពនៃសំណើសុំឲ្យទទួលយកភស្តុតាងបន្ថែមនោះទេ ព្រោះថាវាត្រូវបានអះអាងទាំងស្រុងនៅក្នុងបណ្តឹងសាទុក្ខ[6]។

## II. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងកាលបរិច្ឆេទកំណត់សម្រាប់សំណើសុំភស្តុតាងថ្មី ដោយបានបញ្ជាក់ពីកាតព្វកិច្ចជាបន្តរបស់សហព្រះរាជអាជ្ញា ក្នុងការកំណត់អត្តសញ្ញាណលើសម្ភារៈដោះបន្ទុកជាសក្តានុពល នៅក្នុងការកាន់កាប់របស់ខ្លួន រហូតដល់ចុងបញ្ចប់នៃសំណុំរឿង០០២/០២ និងឲ្យមេធាវីការពារក្តីចំនួនពីរសប្តាហ៍ដើម្បី

[4] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ. លើកទី៩) ដូចដែលបានពិនិត្យសាឡើងវិញ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង”) វិធាន ១០៨(៧)។

[5] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[6] *សូមមើល ឧទា.* ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ១៩ (ពាក់ព័ន្ធនឹងថាតើការលើកឡើងរបស់ ខៀវ សំផន អំពីការដឹងឮពីការចាប់ខ្លួនរបស់ភាគីដែលលេចធ្លោ បង្ហាញសក្ខីកម្មពីការការដឹងឮរបស់គាត់ពីឧក្រិដ្ឋកម្ម ដែរឬយ៉ាងណា) កថាខណ្ឌ ៣១-៣៤ (ពាក់ព័ន្ធនឹងភាពសមហេតុសមផលនៃភាពជឿជាក់របស់អង្គជំនុំជម្រះនៅលើ បទសម្ភាសមួយរបស់ VOA និងការខកខានរបស់ខ្លួនក្នុងការពិចារណាលើការបកស្រាយភស្តុតាងផ្សេងៗ ដែលគួរឲ្យជឿជាក់បាន) កថាខណ្ឌ ៥៧ (ដោយអះអាងថាអង្គជំនុំជម្រះធ្វើជាមិនដឹងមិនឮពីសក្ខីកម្មសវនាការដោះបន្ទុករបស់ ជួន ធី) កថាខណ្ឌ ៦៤ (ដោយតវ៉ាថាអង្គជំនុំជម្រះមិនបានវាយតម្លៃពីសក្ខីកម្មសវនាការរបស់ ជួន ធី) កថាខណ្ឌ ៦៦ (ពាក់ព័ន្ធនឹងការខកខានរបស់អង្គជំនុំជម្រះក្នុងការទាញយក “សេចក្តីសន្និដ្ឋានចាំបាច់” ពីសក្ខីកម្មរបស់សាក្សីផ្សេងៗទៀត) កថាខណ្ឌ ៦៧-៧០ (ដោយអះអាង ថាគោលការណ៍របស់បក្សដែលបានចែងនៅក្នុងទស្សនាវដ្តី*យុវជន-យុវនារីបដិវត្ត* ផ្ទុយគ្នាទៅនឹងការរកឃើញរបស់អង្គជំនុំជម្រះ លើគោលយោបាយអាពាហ៍ពិពាហ៍ជាតិ)។ ខៀវ សំផន សូម្បីតែបានបង្កប់ន័យថា គាត់បានដាកចេញហួសពីវិសាលភាពនៅពេល ដែលគាត់បានថ្លែងថា៖ “គ្រប់ចំណុចទាំងអស់នេះនឹងមានអធិប្បាយនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី”។ *សូមមើល* ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក កំណត់សម្គាល់ជើងទំព័រលេខ ១៣៩។

ដាក់សំណើសុំមួយតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ជាការឆ្លើយតបទៅនឹងការបិទបញ្ចប់ភស្តុតាងដោះបន្ទុកជាសក្ខានុពល ដែលបានធ្វើឡើងកាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦[7]។

5. នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ទាក់ទងទៅនឹងករណីមួយ ដែលកំពុងតែនៅស៊ើបអង្កេត អ្នកស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") បានស្តាប់ចម្លើយ ជួន ធី[8] ដែលធ្លាប់បានផ្តល់សក្ខីកម្មពីមុននៅក្នុងសំណុំរឿង០០២/០១ និង០០២/០២[9]។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ អ្នកស៊ើបអង្កេត ក.ស.ច.ស បានស្តាប់ចម្លើយ ឯក ហេន[10] ដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ នៅឆ្នាំ២០១៣[11]។

6. នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូង (ហៅថា "អង្គជំនុំជម្រះ" ផងដែរ) បានប្រកាសការបិទកិច្ចដំណើរការនីតិវិធីភស្តុតាងលើសំណុំរឿង០០២/០២ និងដកហូតនូវការសម្រេចសាលក្រម[12]។

---

[7] ឯកសារ **E421/4** សេចក្តីសម្រេចលើសំណើសុំស្តីពី កាលបរិច្ឆេទកំណត់ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ("សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់") កថាខណ្ឌ ១, ៩, ២៣-២៥, ផ្នែកសម្រេចសេចក្តី។

[8] **E319/71.2.4** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ដែលនៅពេលនោះ គឺជាសំណុំរឿងលេខ០០៣-ឯកសារ **D114/303** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី។ កំណត់ត្រាស្តាប់ចម្លើយជាខ្សែអាត់សម្លេងដែលត្រូវគ្នា គឺសំណុំរឿងលេខ០០៣-ឯកសារ **D114/303R**។

[9] ឯកសារ **E1/183.1** ជួន ធី ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣, ឯកសារ **E1/489.1** ជួន ធី (2-TCW-859) ប្រតិចារឹក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ន ធី (2-TCW-859) ប្រតិចារឹក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦។ កំណត់ហេតុពីមុនចំនួនពីររបស់ ជួន ធី ក៏ត្រូវបានទទួលយកជាភស្តុតាងផងដែរ៖ ឯកសារ **E3/4593** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១០, ឯកសារ **E3/10713** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥។

[10] ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ដែលនៅពេលនោះ គឺសំណុំរឿងលេខ០០៤-ឯកសារ **D219/940** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន។ កំណត់ត្រាស្តាប់ចម្លើយជាខ្សែអាត់សម្លេងដែលត្រូវគ្នាគឺ សំណុំរឿងលេខ០០៤-ឯកសារ **D219/940R**។

[11] ឯកសារ **E1/217.1** ឯក ហេន ប្រតិចារឹក ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣។ ឯក ហេន ក៏បានផ្តល់នូវកំណត់ហេតុស្តាប់ចម្លើយចំនួនពីរពីមុនដែលត្រូវបានទទួលយកជាភស្តុតាងផងដែរ៖ ឯកសារ **E3/4635** ឯក ហេន កំណត់ហេតុសម្ភាសរបស់ DC-Cam ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៣ ឯកសារ **E3/474** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៨។ *សូមមើល ផងដែរ* ឯកសារ **D94/8R** ដែលជាកំណត់ត្រាស្តាប់ចម្លើយជាខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយ ឯកសារ **E3/474** និងឯកសារ **D94/8.1** ដែលជាប្រតិចារឹកនៃកំណត់ត្រាស្តាប់ចម្លើយជាខ្សែអាត់សម្លេង។

[12] ឯកសារ **E1/528.1** សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ប្រតិចារឹក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង៖ 11.09.45-11.11.13។

7. នៅថ្ងៃទី២៧ ខែមិថុនា និងនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ កំណត់ហេតុស្តាប់ចម្លើយពី ឯក ហេន និង ជួន ធី ទៅជាមានបាននៅក្នុង Zylab ជាភាសាអង់គ្លេស ដោយរៀងៗខ្លួន[13]។

8. នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយចំនួនប្រាំបី[14] ដែលត្រូវបានផ្តល់ឱ្យដោយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនានា ដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ និង/ឬ សំណុំរឿង០០២/០២ ហើយក្រោយមកត្រូវបានស្តាប់ចម្លើយទាក់ទងនឹងសំណុំរឿងផ្សេងៗទៀត[15]។ រួមបញ្ចូលនៅក្នុងកំណត់ហេតុស្តាប់ចម្លើយចំនួនប្រាំបី គឺមានកំណត់ហេតុស្តាប់ចម្លើយនៅខែកុម្ភៈ និងខែមីនា ឆ្នាំ២០១៧ របស់ ជួន ធី និង ឯក ហេន រៀងៗខ្លួន។ ស.ព.អ បានដាក់ឯកសារដាក់បង្ហាញនានា នៅក្នុងសំណុំឯកសារមួយនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមរបស់តុលាការ ដែលអាចចូលមើលបានចំពោះក្រុមមេធាវីការពារក្តីនៃសំណុំរឿង០០២ និងអង្គជំនុំជម្រះសាលាដំបូងសម្រាប់ពិនិត្យសាឡើងវិញ និងចំណាត់ការជាបន្តបន្ទាប់ដែលសន្មតថាការត្រឹមត្រូវ[16]។

9. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម និងការកាត់ទោសរបស់ខ្លួននៅក្នុងសំណុំរឿង០០២/០២ ដោយបានផ្តល់នូវសេចក្តីសង្ខេបផ្ទាល់មាត់មួយស្តីពីការសន្និដ្ឋាន និងការសម្រេចសេចក្តីរបស់ខ្លួន។ អង្គជំនុំជម្រះនេះបានថ្លែងថា សម្អាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់នៃការសន្និដ្ឋានរបស់ខ្លួន នឹងត្រូវបានធ្វើឡើងនៅក្នុងសាលក្រមជាលាយ

---

[13] សំណៅជាភាសាខ្មែរនៃកំណត់ហេតុស្តាប់ចម្លើយ ឯក ហេន (សំណុំរឿង០០៤-ឯកសារ **D219/940**) អាចរកបាននៅក្នុង Zylab ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ រីឯសំណៅជាភាសាខ្មែរនៃ កំណត់ហេតុស្តាប់ចម្លើយ ជួន ធី (សំណុំរឿង០០៣-ឯកសារ **D114/303**) អាចរកបាននៅ ក្នុង Zylab ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧។

[14] ឯកសារនានាមាន កំណត់ហេតុស្តាប់ចម្លើយចំនួនប្រាំ ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីមួយច្បាប់ និងទម្រង់ព័ត៌មានបន្ថែមចំនួនពីរច្បាប់។ *សូមមើល* ឯកសារ **E319/71** ការស្នើសុំដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ("សេចក្តីជូនដំណឹងស្តីពីការដាក់បង្ហាញ") កថាខណ្ឌ ១។

[15] ឯកសារ **E319/71** សេចក្តីជូនដំណឹងស្តីពីការដាក់បង្ហាញ កថាខណ្ឌ ១។ ដូចដែលបានកត់សម្គាល់នៅក្នុងឯកសារ **E319/71** សេចក្តីជូនដំណឹងស្តីពីការដាក់បង្ហាញ កំណត់សម្គាល់ជើងទំព័រលេខ ១ ទាំងអស់ ប៉ុន្តែឯកសារចំនួនពីរក្នុងចំណោមឯកសារទាំងនោះត្រូវបានចុះកាលបរិច្ឆេទ បន្ទាប់ពីបុគ្គលនោះបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២ ហើយការលើកលែងទាំងពីរនោះបានដាក់ឈ្មោះរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីខុសគ្នាពីឈ្មោះដែលបានប្រើនៅក្នុងសំណុំរឿង០០២។

[16] ឯកសារ **E319/71** សេចក្តីជូនដំណឹងស្តីពីការដាក់បង្ហាញ កថាខណ្ឌ ១ កំណត់សម្គាល់ជើងទំព័រលេខ ៣ (ដោយបានសម្គាល់ផ្លូវថាជា G:\OCP Proposed Disclosure\20180903 Proposed Disclosure)។

លក្ខណ៍អក្សរក្នុងពេលសមស្របខាងមុខ[17]។ សាលក្រមជាលាយលក្ខណ៍អក្សរ ("សាលក្រម") នោះ បន្ទាប់មកត្រូវបានចេញជាភាសាខ្មែរ អង់គ្លេស និងបារាំង នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩[18]។

10. នៅក្នុងការឆ្លើយតបទៅនឹងសំណើសុំពន្យារពេល និងចំនួនទំព័រ របស់ នួន ជា និង ខៀវ សំផន[19] អ.ជ.ត.ក បានផ្តល់ដល់គ្រប់ភាគីទាំងអស់នៃសំណុំរឿង០០២/០២ ឱ្យដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ខ្លួន រហូតដល់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩[20]។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងរបស់ខ្លួន ដោយបានបញ្ជាក់ពីទឡ្ហីករណ៍មួយចំនួននៃបណ្តឹងសាទុក្ខរបស់ខ្លួន[21]។ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខរបស់គាត់ ដោយបានលើកឡើងពីកំហុសចំនួន ១៨២៤ របស់អង្គជំនុំជម្រះសាលាដំបូង[22]។

11. នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ខៀវ សំផន បានស្នើសុំឱ្យ អ.ជ.ត.ក ទទួលយកកំណត់ហេតុស្តាប់ចម្លើយ ជួន ធី និង ឯក ហេន ដែលត្រូវបានដាក់បង្ហាញកាលពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ ក៏ដូចជាកំណត់ត្រាស្តាប់ចម្លើយជាខ្សែអាត់សម្លេងរបស់ពួកគេផងដែរ (ជារួម ហៅថា "ភស្តុតាងដែលបានស្នើសុំ")[23]។

## III. ច្បាប់ជាធរមាន

---

[17] ឯកសារ **E1/529.1** ប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង៖ 09:34:35-09:36:02។

[18] ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សាលក្រមសំណុំរឿង០០២/០២")។

[19] ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។ ឯកសារ **F40/1.1** សំណើបន្ទាន់លើទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែម សម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង០០២/០២ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។

[20] ឯកសារ **F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១១,១៣។

[21] ឯកសារ **E465/2/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។

[22] ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ របស់លោក ខៀវ សំផន (សំណុំរឿង០០២/០២) ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

[23] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៥,៧៨។

12. លក្ខខណ្ឌតម្រូវទូទៅសម្រាប់ការទទួលយកភស្តុតាងត្រូវបានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធាន ផ្ទៃក្នុង ដែលបានចែងផងដែរថា អង្គជំនុំជម្រះអាចបដិសេធសំណើសុំឱ្យទទួលយកភស្តុតាង កាលណាអង្គជំនុំជម្រះ៖

ក. មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា

ខ. មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ. មិនស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ. ច្បាប់មិនអនុញ្ញាត ឬ

ង. មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍[24]។

13. សំណើសុំការអនុញ្ញាតឱ្យទទួលយកភស្តុតាងបន្ថែមនៅក្នុងបណ្តឹងសាទុក្ខ ត្រូវបានចែងបន្ថែមទៀត នៅក្នុងវិធាន ១០៨(៧) ដែលបានចែង នៅក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក[25]។

14. អ.ជ.ត.ក បានរកឃើញថា ក្នុងគោលបំណងដើម្បីបង្ហាញថាផ្នែកនៃភស្តុតាងបន្ថែមដែលបានស្នើសុំនេះ អាចជាកត្តាសម្រេចមួយនោះ៖

> [...] ភាគីដែលស្នើសុំភស្តុតាងត្រូវតែបង្ហាញថាថា ភស្តុតាងនេះ ប្រសិនបើបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អាចនាំឱ្យអង្គជំនុំជម្រះនេះ ធ្វើការសម្រេចពីពិរុទ្ធភាពខុសប្លែកពីមុនទាំងស្រុង ឬផ្នែកខ្លះ។ ក្នុងការវាយតម្លៃបែបនេះ ភស្តុតាងបន្ថែមដែលបានស្នើឡើង ត្រូវតែបានវាយតម្លៃទៅតាមបរិបទនៃភស្តុតាង ដែលបានដាក់នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការយល់ឃើញផ្នែកអង្គហេតុ ដែលមានលក្ខណៈសំខាន់ ឬចាំបាច់បំផុតចំពោះការសម្រេចដាក់ពិរុទ្ធភាព ឬការប្រកាសទោស។ អាស្រ័យ

[24] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[25] វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។

លើភាគីដែលស្នើសុំដាក់ភស្តុតាងបន្ថែម ក្នុងការបង្ហាញពីឥទ្ធិពលរបស់ភស្តុតាងដែលបានស្នើសុំដាក់បន្ថែមនោះ[26]។

15. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង បានចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា "អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី ដើម្បីធ្វើការសម្រេចលើបញ្ហានេះ"[27]។ អ.ជ.ត.ក បានរក្សាថា "មិនត្រូវប៉ះពាល់ដល់សម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ" ដោយបានព្រមព្រៀងទៅនឹងវិធីសាស្ត្រទូទៅនៃតុលាការ ICTY ដែលផ្តល់នូវសេចក្តីគោរពដែលមានកម្រិតចំពោះការរកឃើញខាងអង្គហេតុ ដែលបានឈានដល់ដោយអ្នកកាត់សេចក្តីខាងអង្គហេតុ[28]។ វិធីសាស្ត្រនេះទទួលស្គាល់ថា "កិច្ចការសវនាការ ការវាយតម្លៃ និងការថ្លឹងថ្លែងភស្តុតាងដែលបានបង្ហាញនៅពេលសវនាការ គឺត្រូវទុកជាចម្បងឲ្យអង្គជំនុំជម្រះសាលាដំបូង" ពីព្រោះអង្គជំនុំជម្រះនេះ "មានអត្ថប្រយោជន៍ក្នុងការពិនិត្យសាក្សីជាបុគ្គលផ្ទាល់ ហើយដូច្នេះ នឹងមានគោលជំហរប្រសើរជាងអង្គជំនុំជម្រះតុលាការកំពូល ក្នុងការវាយតម្លៃលើភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាននៃភស្តុតាង"[29]។

16. វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ចែងថា៖ "ក្នុងរយៈពេលឆាប់ដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាត្រូវបង្ហាញ [...] នូវសម្ភារៈទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសម្ភារៈ

---

[26] ឯកសារ **F36** សាលដីកាលើសំណុំរឿង០០២/០១ កថាខណ្ឌ ៣០។

[27] វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

[28] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៧ *ដោយបានលើកឡើងពី រដ្ឋអាជ្ញា ទល់នឹង Kupreškić តួកន* IT-95-16-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ ("សាលដីកា *Kupreškić*") កថាខណ្ឌ ៣០, ៣២។ ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាលើសំណុំរឿង ០០២/០១") កថាខណ្ឌ ៨៩។ *សូមមើល ផងដែរ រដ្ឋអាជ្ញា ទល់នឹង Blaškić* IT-95-14-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៧។ *រដ្ឋអាជ្ញា ទល់នឹង Krstić* IT-98-33-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ៤០។

[29] *សូមមើល ឧទា. សាលដីកា Kupreškić* កថាខណ្ឌ ៣០, ៣២។ *រដ្ឋអាជ្ញា ទល់នឹង Kvočka តួកន* IT-98-30/1-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ៤២៧។ សាលដីកា *Rutaganda* កថាខណ្ឌ ២១។ *រដ្ឋអាជ្ញា ទល់នឹង Kajelijeli* ICTR-98-44A-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ៥០។ *រដ្ឋអាជ្ញា ទល់នឹង Munyakaz,* ICTR-97-36A-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១១៨, ១៥៤។

ទាំងនេះ នឹងអាចនាំឱ្យគ្មានពិរុទ្ធភាព ឬសម្រាលពិរុទ្ធភាពនៃជនសង្ស័យ ឬជនត្រូវចោទ ឬធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់នៃភស្តុតាងក្នុងការចោទប្រកាន់”[30]។

## IV. សារណា

### ក. សំណើសុំការអនុញ្ញាតឱ្យទទួលយកនេះគួរត្រូវបានច្រានចោលដោយសារមិនទាន់ពេលវេលា

17. សំណើសុំការអនុញ្ញាតឱ្យទទួលយកនេះមិនត្រូវពេលវេលាទេ ដោយសារតែមេធាវីការពារក្តីមិនបានប្រើឱកាសដែលខ្លួនមាន ដើម្បីស្វែងរកការអនុញ្ញាតឱ្យទទួលយកភស្តុតាងដែលបានស្នើឡើងនេះ បន្ទាប់ពីត្រូវបានដាក់បង្ហាញ និងនៅមុនពេលដែលសាលក្រមសំណុំរឿង០០២/០២ ត្រូវបានចេញ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះកាលបរិច្ឆេទថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានប៉ាន់ប្រមាណការដាក់បង្ហាញដែលកំពុងបន្ត ដែលបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគីនានាធ្វើសារណាទាក់ទងទៅនឹងការអនុញ្ញាតឱ្យទទួលយកភស្តុតាងបន្ថែម និងបានកំណត់ពេលវេលាកំណត់សមហេតុផលស្តីពីការអនុញ្ញាតឱ្យទទួលយកនេះ គឺក្នុងរយៈពេលពីរសប្តាហ៍ទទួលនៃការទទួលបានសម្ភារៈដែលត្រូវបានដាក់បង្ហាញ[31]។

18. ជាក់ស្តែង អង្គជំនុំជម្រះបានរម្លឹកថា ជនជាប់ចោទមាន “សិទ្ធិជាមូលដ្ឋានក្នុងការចូលពិនិត្យសម្ភារៈដែលអាចមានលក្ខណៈដោះបន្ទុក” ខណៈដែលកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាត្រូវដាក់បង្ហាញសម្ភារៈបែបនោះ “មិនមែនអាស្រ័យទៅលើពេលវេលាកំណត់ណាមួយឡើយ” ហើយអាចបន្ត “រហូតដល់ពេលបញ្ចប់សំណុំរឿង០០២/០២”[32]។ អង្គជំនុំជម្រះបានទទួលស្គាល់យ៉ាងច្បាស់លាស់ថា កត្តាទាំងនេះ “មេធាវីការពារក្តីអាចធ្វើសំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅក្រោយកាលបរិច្ឆេទកំណត់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ នេះ”[33] ហើយប្រសិនបើពួកគេបានធ្វើនោះ “មេធាវីការពារក្តីត្រូវតែឆ្លើយតបចំពោះការដាក់បង្ហាញភស្តុតាងដែលអាចដោះបន្ទុក ដែលធ្វើឡើងក្រោយថ្ងៃ

---

[30] វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង។ *សូមមើល ផងដែរ* ឯកសារ **F2/4/2** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ (“សេចក្តីសម្រេចលើសំណើលើកទីបី”) កថាខណ្ឌ ១៧។

[31] ឯកសារ **E421/4** សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ ១៥ (បានថ្លែងថា ខ្លួនមិនអាចទុកឱ្យកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នបើកចំហរសម្រាប់ភស្តុតាងថ្មីដោយគ្មានទីបញ្ចប់នោះទេ ប៉ុន្តែបានអនុញ្ញាតសម្រាប់ករណីលើកលែង) ២៣-២៤។

[32] ឯកសារ **E421/4** សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ ៩។

[33] ឯកសារ **E421/4** សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ ១៩។

ទី០១ ខែកញ្ញា ឆ្នាំ២០១៦ តាមរយៈសំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង *ក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីទទួលបានការដាក់បង្ហាញ*"[34]។

19. ដូច្នេះ ផ្ទុយគ្នាទាំងស្រុងពីការចោទប្រកាន់របស់ ខៀវ សំផន ដែលថាអង្គជំនុំជម្រះនេះ ចង់ផ្តន្ទាទោស ខៀវ សំផន ក្នុងតម្លៃណាមួយ ហើយហេតុដូច្នេះបានរំលោភកាតព្វកិច្ចរបស់ខ្លួនដោយចេតនាតាមរយៈការខកខានមិនបានបើកឲ្យមានកិច្ចដំណើរការនីតិវិធីឡើងវិញនោះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ដំណោះស្រាយ តែទោះជាយ៉ាងណា ដំណោះស្រាយនោះមេធាវីការពារក្តីខកខានមិនបានទទួលយក[35]។ តាមពិត សេចក្តីសម្រេចនេះបង្ហាញឲ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះ ដើម្បីរក្សានូវសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងសមភាពនៃការតតាំងក្តី[36]។ ក៏បានកំណត់ការរំពឹងទុកសម្រាប់មេធាវីការពារក្តីធ្វើ។ អង្គជំនុំជម្រះបានរម្លឹកភាគីនានាថា "ឯកសារដែលបានដាក់បង្ហាញមិនត្រូវបានទទួលយកជាស្វ័យប្រវត្តិ ឬដាក់ជាស្វ័យប្រវត្តិនៅចំពោះមុខអង្គជំនុំជម្រះឡើយ"[37] មេធាវីការពារក្តី "ស្ថិតក្នុងស្ថានភាពល្អបំផុតក្នុងការសម្រេចថាតើឯកសាមួយណាដែលខ្លួនពិចារណាថាជាឯកសារដោះបន្ទុក"[38] ហើយ "ជាឆន្ទានុសិទ្ធិរបស់មេធាវីការពារក្តីក្នុងការស្នើសុំ ឬមិនស្នើសុំឲ្យទទួលយកឯកសារ [ដាក់បង្ហាញ] ទាំងអស់នេះ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង"[39]។

20. មេធាវីការពារក្តីខកខានមិនបានធ្វើញត្តិណាមួយសុំការអនុញ្ញាតឲ្យទទួលយកសម្ភារៈដោះបន្ទុក នៅក្រោយការដាក់បង្ហាញនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ នោះទេ ទោះបីជាទទួលបានសម្ភារៈទាំងនេះរយៈពេលជាងពីរខែ មុនពេលដែលអង្គជំនុំជម្រះសាលាដំបូងប្រកាស់សាលក្រមរបស់ខ្លួន។ ហើយមេធាវីការពារក្តីក៏មិនបានសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបើកកិច្ចដំណើរការនីតិវិធីឡើងវិញ ដោយយោងទៅលើកាលៈទេសៈពិសេសនោះទេ និងសម្រាប់គោលបំណងមានកំណត់នៃការប្តឹងតវ៉ាចំពោះកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានដាក់បង្ហញទាំងនោះឡើយ។ ប្រសិនបើមេធាវីការពារក្តីបានធ្វើញត្តិស្នើសុំតាមពេលវេលាបែបដូច្នេះនោះ អង្គជំនុំជម្រះសាលាដំបូងនឹងមានឱកាសធ្វើការសម្រេច

---

[34] ឯកសារ E421/4 សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ ២៣-២៤ (ការដកស្រង់ត្រង់កថាខណ្ឌ២៣ គូសបញ្ជាក់បន្ថែម)។

[35] ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ១២, ១៤។

[36] *សូមមើ ឧទាហរណ៍* ឯកសារ E421/4 សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ ៩, ១៤, ១៩។

[37] ឯកសារ E421/4 សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ ៩។

[38] ឯកសារ E421/4 សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ១០។

[39] ឯកសារ E421/4 សេចក្តីសម្រេចលើកាលបរិច្ឆេទកំណត់ កថាខណ្ឌ ១១។

លើបញ្ហានេះមុនពេលខ្លួនចេញសាលក្រមរបស់ខ្លួន និងទទួលយកឯកសារទាំងនោះមកពិចារណា ប្រសិនបើខ្លួនជឿជាក់ថាការធ្វើតេស្តពីភាពអាចទទួលយកបានត្រូវបានបំពេញ។ ទោះបីជាយ៉ាងនេះក៏ដោយ ពេលនេះ ខៀវ សំផន បន្ទោសអង្គជំនុំជម្រះសាលាដំបូង ចំពោះការខកខានមិនបានបើកកិច្ចដំណើរការនីតិវិធីឡើងវិញ នៅពេលដែល*ភាគីពាក់ព័ន្ធ*នេះស្ថិតនៅលើមេធាវីការពារក្តីត្រូវធ្វើ ឬត្រូវជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីអង្គហេតុដែលថាខ្លួនយល់ឃើញថា ភស្តុតាងដែលត្រូវបានស្នើសុំនោះមានសារៈសំខាន់។

## ខ. សំណើសុំការអនុញ្ញាតឲ្យទទួលយកនេះ គួរត្រូវបានច្រានចោល ដោយសារតែភស្តុតាងដែលត្រូវបានស្នើសុំនេះ មិនអាចជាកត្តាកំណត់ក្នុងការធ្វើសេចក្តីសម្រេចនៅពេលជំនុំជម្រះទេ

21. បន្ថែមលើនេះ ការដាក់សំណើមិនត្រូវតាមវេលាដូចដែលបានពិភាក្សាខាងលើនេះ សំណើសុំការអនុញ្ញាតឲ្យទទួលយកនេះ គួរត្រូវបានបដិសេធចោល ដោយសារខកខានមិនបានបំពេញតាមបទដ្ឋានតឹងរ៉ឹងសម្រាប់ភាពអាចទទួលយកបាននៃភស្តុតាងថ្មីនៅដំណាក់កាលបណ្តឹងសាទុក្ខ។

22. *ជាប្រយោជន៍នៃទឡ្ហីករណ៍*សន្មតថាភស្តុតាងដែលត្រូវបានស្នើឡើងមិនអាចរកបាននៅពេលជំនុំជម្រះ សំណើសុំការអនុញ្ញាតឲ្យទទួលយកនេះ គួរត្រូវបានបដិសេធចោល ដោយសារតែខកខានមិនបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ភាពអាចទទួលយកបាននៃភស្តុតាងថ្មី នៅដំណាក់កាលបណ្តឹងសាទុក្ខ។ ក្នុងបរិបទភស្តុតាងនៃរឿងក្តីនេះ ភស្តុតាងដែលត្រូវបានស្នើឡើង មិនអាចជាកត្តាកំណត់ក្នុងការធ្វើសេចក្តីសម្រេចនេះនៅពេលជំនុំជម្រះទេ ដោយសារតែ ខៀវ សំផន មិនបានបង្ហាញលទ្ធភាពច្បាស់លាស់ដែលថា ប្រសិនបើវាត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ វានាំឲ្យអង្គជំនុំជម្រះនេះចេញសាលក្រមផ្សេងទាំងមូល ឬដោយផ្នែក។

### ១. ឯក ហេន

### *ក. កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ឯក ហេន មិនអាចជាកត្តាកំណត់សម្រាប់ការសន្និដ្ឋាន ដែលក្នុងនោះភស្តុតាងរបស់គាត់ត្រូវបានដកស្រង់ផ្ទាល់នោះទេ*

23. ខៀវ សំផន ចោទប្រកាន់ខុសថា កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ឯក ហេន បញ្ជាក់ពីកង្វះខាតភាពអាចជឿជាក់បានរបស់គាត់ ហើយហេតុដូច្នេះ អង្គជំនុំជម្រះមិនគួរណាផ្អែកលើភស្តុតាងណាមួយរបស់គាត់ ដែលថាបានគាំទ្រដល់ការសន្និដ្ឋានជាច្រើននោះទេ[40]។ ដូចដែលបានកត់សម្គាល់ខាង

[40] ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ១៦។

លើ បទសម្ភាសន៍ DC-Cam របស់ ឯក ហេន កំណត់ហេតុស្តាប់ចម្លើយពីមុន និងសក្ខីកម្ម សវនាការសំណុំរឿង០០២/០១ ត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង០០២/០២ទាំងអស់ មុនពេលអង្គជំនុំជម្រះធ្វើការពិភាក្សា[41]។ ដូច្នេះ អង្គជំនុំជម្រះ បានដោះស្រាយចាំបាច់អំពីភាពជាន់គ្នាដែលបានលើកឡើងតាមរយៈការរៀបរាប់ទាំងបី ធៀបទៅនឹងភស្តុតាងទាំងមូល ដោយបានទទួលយកអ្វីដែលខ្លួនបានរកឃើញថាអាចជឿជាក់បាន និងដោយបដិសេធអ្វីដែលមិនអាចជឿជាក់បាន[42]។ ថាតើការវាយតម្លៃរបស់អង្គជំនុំជម្រះនេះសមហេតុផល ឬយ៉ាងណានោះ គឺជាបញ្ហាក្នុងបណ្តឹងសាទុក្ខដែលហួសពីវិសាលភាពនៃចម្លើយតបនេះ។ អ្វីដែលពាក់ព័ន្ធនោះគឺ ថាតើកំណត់ហេតុនៃការស្តាប់ចម្លើយថ្មីនេះ ផ្ទុយគ្នាទៅនឹងការសន្និដ្ឋានដែលបានផ្អែកលើភស្តុតាងពីមុនរបស់ ឯក ហេន ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលយក ឬទេ[43]។

24. ឧទាហរណ៍ សាលក្រមបានដកស្រង់សក្ខីកម្មសវនាការរបស់ ឯក ហេន ដើម្បីសន្និដ្ឋានថា៖ “ពេញមួយឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ ប៉ុល ពត និង ខៀវ សំផន បានបន្តសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការការពារ និងថែរក្សាជោគជ័យបដិវត្ត និង “ពូជសាសន៍កម្ពុជា” ពីវៀតណាម “វាទីនិយម” និង “ទេសានុពន្ធន៍និយម””[44]។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់គាត់ ឯក ហេន ប្រកាន់ភ្ជាប់ថា ការប្រជុំនៅបុរីកីឡាដែលដឹកនាំដោយ ខៀវ សំផន បានកើតឡើងក្នុងឆ្នាំ១៩៧៨ ទោះបីជានៅពេល

---

[41] *សូមមើល* ជើងទំព័រ ១១ *យោងខាងលើ*។

[42] *សូមមើលឧទាហរណ៍* ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ២២-២៣, ២៦-២៧, ៣០។ វាត្រូវបានបង្ហាញយ៉ាងច្បាស់ថា ការវាយតម្លៃលើភាពអាចជឿជាក់បានពាក់ព័ន្ធទៅនឹងការកំណត់បែបអត្តនោម័តជាច្រើនដែលស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិយ៉ាងពេញលេញរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងនាមជាអ្នកស្វែងរកការពិតដំបូងគេ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែដោះស្រាយភាពមិនស៊ីចង្វាក់គ្នាណាមួយ ដែលអាចកើតមានឡើងនៅក្នុង និង/ឬ ក្នុងចំណោមសក្ខីកម្មរបស់សាក្សី។ ការបដិសេធ លក្ខណៈជាមូលដ្ឋាននៃភស្តុតាង មិនរារាំងអង្គជំនុំជម្រះមិនឱ្យទទួលយកទិដ្ឋភាពផ្សេងទៀតឡើយ ហើយក៏មិនតម្រូវឱ្យអង្គជំនុំជម្រះបដិសេធភស្តុតាងនោះទាំងស្រុងដែរ។ *សូមមើឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Popović និងគូកន*, IT-05-88-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលក្រម, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១៣១-១៣២, ១៣៦-១៣៧, ១២២៨។ *Nchamihigo ទល់នឹង រដ្ឋអាជ្ញា* ICTR-2001-63-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកា ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ កថាខណ្ឌ ៤៧។ *Nahimana និងគូកន ទល់នឹង រដ្ឋអាជ្ញា* ICTR-99-52-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ១៩៤។ សាលដីកា *Rutaganda* កថាខណ្ឌ ៣៥៣, ៤៤៣, ៥០១។ *Muvunyi ទល់នឹង រដ្ឋអាជ្ញា*, ICTR-2000-55A-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៦។ សាលដីកា *Kupreškić*, កថាខណ្ឌ ៣១។

[43] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ២៤ (អះអាងថាមាន “ភាពផ្ទុយគ្នាថ្មីៗ” នៅក្នុងកំណត់ហេតុស្តាប់ចម្លើយថ្មី)។

[44] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៤០៦ ជើងទំព័រ ១១៤៨៤។

ដែលគាត់ត្រូវបានដេញដោល ដោយអ្នកស៊ើបអង្កេតក៏ដោយ[45]។ ឯក ហេន ក៏បាននិយាយផងដែរថា "គាត់ [ខៀវ សំផន] បានលើកឡើងថា យើងត្រូវការពារទឹកដីយើង កុំឲ្យបានទៅយួន"[46]។ កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ឯក ហេន ស្របគ្នាយ៉ាងខ្លាំងជាមួយនឹងការរកឃើញរបស់អង្គជំនុំជម្រះ ដែលថា ប្រសិនបើវាមាននៅចំពោះមុខអង្គជំនុំជម្រះ គ្មានលទ្ធភាពច្បាស់លាស់ណាដែលវាអាចនាំឲ្យអង្គជំនុំជម្រះចេញសាលក្រមផ្សេងនេះទេ។

25. ការវិភាគស្រដៀងគ្នាអំពីការរកឃើញទាំងប្រាំបួនរបស់សាលក្រម ដែលដកស្រង់ភស្តុតាងរបស់ ឯក ហេន ស្តីពីការប្រជុំនៅបុរីកីឡា បញ្ជាក់ថា កំណត់ហេតុស្តាប់ចម្លើយថ្មីនេះ ត្រូវគ្នាជាមួយនឹងការរកឃើញទាំងអស់នោះ ហើយដូច្នេះ មិនអាចជាកត្តាកំណត់ក្នុងការចេញសាលក្រមនេះទេ[47]។

---

[45] ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ឆ.៤៣-៤៤, ៤៦-៤៧។

[46] ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ឆ.៥១។

[47] ***ការសម្រេច ១:*** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៤០៦, កំណត់សម្គាល់ជើងទំព័រ ១១៤៨៤ ដូចបានរៀបរាប់យ៉ាងលម្អិតខាងលើ។ ***ការសម្រេច ២:*** ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៦០៧, កំណត់សម្គាល់ជើងទំព័រ ១៩០៤ ("សិក្ខាកាមចូលរួមមានចាប់ពីយុទ្ធជនរហូតដល់កម្មាភិបាល បកក និងអ្នកត្រឡប់ពីបរទេស ដែលមានចំនួនចាប់ពីរាប់សិបនាក់រហូតដល់រាប់ពាន់នាក់ ដោយពួកគេបានទទួលការបង្រៀនផ្សេងៗអំពីគោលការណ៍បដិវត្តន៍ សហករណ៍ បច្ចេកទេសកសិកម្ម និងបញ្ហាសេដ្ឋកិច្ច ដោយ ខៀវ សំផន បានបង្រៀនពីវិធីកំណត់អត្តសញ្ញាណ "ខ្មាំង" និងស្វែងរក "ជនក្បត់") *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ឆ:៣៩-៤០ (ទាក់ទងនឹងចំនួនកម្មករដែលបានចូលរួមវគ្គរៀនសូត្រ) ឆ:៤២ (ការបង្រៀនកម្មករអំពីគោលការណ៍បដិវត្តន៍ក្នុងការខំប្រឹងធ្វើការងារដើម្បីកសាងប្រទេសឲ្យរីកចម្រើន)។ ***ការសម្រេច ៣:*** ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២, កថាខណ្ឌ ៣២១៦, កំណត់សម្គាល់ជើងទំព័រ ១០៨២៥ ("ខៀវ សំផន ក៏បានសង្កត់ធ្ងន់អំពីសារសំខាន់នៃការការពារ និងការថែរក្សា "ផ្លែផ្កានៃបដិវត្តន៍ និងជាតិសាសន៍កម្ពុជាឲ្យបានជារៀងរហូត" នៅក្នុងសុន្ទរកថារបស់គាត់ផងដែរ") *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ឆ:៤២ (លើកទឹកចិត្តឲ្យកម្មករខំប្រឹងធ្វើការងារដើម្បីកសាងប្រទេសឲ្យរីកចម្រើន) ឆ:៤៩ (និយាយអំពីការរស់នៅឲ្យចេះសាមគ្គីគ្នា និងកុំឲ្យក្បត់គ្នា), ឆ:៥១ (និយាយអំពីការការពារទឹកដី កុំឲ្យបានទៅគេ)។ ***ការសម្រេច ៤:*** ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២, កថាខណ្ឌ ៣៣៩០, កំណត់សម្គាល់ជើងទំព័រ ១១៤៣៦ ("អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មពីសាក្សីមួយចំនួនដែលបានបញ្ជាក់ថា ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ ប៉ុល ពត, នួន ជា, ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់របស់ បកក ដទៃទៀត បានបង្រៀន ឬចូលរួមវគ្គបណ្តុះ បណ្តាលផ្នែកនយោបាយ ដែលពេលនោះ វៀតណាម ឬ "ភ្នាក់ងារ"វៀតណាម ត្រូវបានចាត់ទុកថាជាខ្មាំង") *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន, ឆ:៤៣-៤៤, ៤៦-៤៧, ៥១។ ***ការសម្រេច ៥:*** ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២, កថាខណ្ឌ ៣៣៩០, កំណត់សម្គាល់ជើងទំព័រ ១១៣៤៧ ("សាក្សី ឯក ហេន ដែលជាអ្នកធ្វើការនៅក្នុងអង្គភាពរោងចក្រកាត់ដេរមួយស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ បានផ្តល់សក្ខីកម្មថា គាត់និងអ្នកចូលរួមផ្សេងទៀតប្រហែល ៤០០ ទៅ ៥០០ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលមួយដែលធ្វើឡើងដោយ ខៀវ សំផន ដែលពេលនោះ គាត់បានពន្យល់ថា "យើងត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន") *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន, ឆ:៣៩-៤០, ៥១។ ***ការសម្រេច ៦:*** ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២, កថាខណ្ឌ

## *ខ. កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ឯក ហេន មិនអាចជាកត្តាកំណត់សម្រាប់ការរកឃើញ ដែលក្នុងនោះ ភស្តុតាងរបស់គាត់ត្រូវបានសម្អាងលើជាផ្នែកមួយនៃរូបភាពដ៏ធំនោះទេ*

26. វាអនុវត្តតាមយ៉ាងត្រឹមត្រូវថា ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ឯក ហេន មិនបានប៉ះពាល់ដល់ការរកឃើញនានា សម្រាប់អ្វីដែលរូបគាត់ត្រូវបានដកស្រង់ ដូចដែលបានបង្ហាញខាងលើ ការរកឃើញដ៏ធំជាងនេះដែលបង្កើតឡើងពីការរកឃើញ (ដែលមិនត្រូវបានប៉ះពាល់) ទាំងនេះ ក៏នឹងមិនត្រូវបានប៉ះពាល់ផងដែរ។ ជាងនេះទៀត សាលក្រមបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន លើភស្តុតាងទាំងមូល ហើយការប្រជុំនៅបុរីកីឡាគ្រាន់តែជាផ្នែកមួយនៃរូបភាពដ៏ធំមួយនៃការដឹងឮរបស់គាត់ ចេតនារបស់គាត់ និងការចូលរួមចំណែករបស់គាត់តែប៉ុណ្ណោះ។ ការវិភាគនៃការរកឃើញនានាអំពីការដឹងឮរបស់ ខៀវ សំផន ដែលកើតឡើងក្រោយការប្រព្រឹត្តឧក្រិដ្ឋកម្ម ពន្យល់អំពីចំណុចនេះ[48]។

---

៣៧៣៩ កំណត់សម្គាល់ជើងទំព័រ ១២៤៧៣ (ប៉ុល ពត, នួន ជា, ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត បានឧទ្ទេសនាមបន្ថែមទៅកម្មាភិបាល នៅក្នុងវគ្គរៀនសូត្រទ្រង់ទ្រាយធំស្តីពីភាពចាំបាច់ក្នុងការខិតខំ “ហួបតិច” និង “សម្រោកតិច” និងបំពេញគោលដៅរបស់បក្ស “ទោះក្នុងតម្លៃណាក៏ដោយ” *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ឆ:៤២ (ខៀវ សំផន លើកទឹកចិត្តពួកគេឲ្យខំប្រឹងធ្វើការងារដើម្បីកសាងប្រទេសឲ្យរីកចម្រើន និងឲ្យចេះសាមគ្គីគ្នា)។ **<u>ការសម្រេច ៧:</u>** ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៩១៦, កំណត់សម្គាល់ជើងទំព័រ ១៣០៧២ (“ទាំង នួន ជា និង ខៀវ សំផន បានបង្រៀនដល់កម្មាភិបាលអំពីការបំពេញគោលដៅសេដ្ឋកិច្ចនិងផលិតកម្ម ហើយ នួន ជា បានផ្តល់ការណែនាំជាក់លាក់ដល់កម្មាភិបាលលើការគ្រប់គ្រងសហករណ៍ ដើម្បីធានាដល់ការបំពេញផែនការ និងបង្កើនចំនួនផលច្រូតកាត់ក្នុងមួយឆ្នាំៗ”) *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ឆ:៤២។ **<u>ការសម្រេច ៨:</u>** ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៣៩៦៨ កំណត់សម្គាល់ជើងទំព័រ ១៣២០៥ (“ទាំង នួន ជា និង ខៀវ សំផន បានបង្រៀនដល់កម្មាភិបាលអំពីសារសំខាន់នៃការធ្វើជីវទស្សន៍ និងលត់ដំ តាមរយៈការទិតៀន និងស្វ័យទិតៀន”) *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន គ្មានចម្លើយពាក់ព័ន្ធការសម្រេចនេះទេ។ **<u>ការសម្រេច ៩:</u>** ឯកសារ **E465** សាលក្រមសំណុំរឿង០០២/០២ កថាខណ្ឌ ៤២៧២, កំណត់សម្គាល់ជើងទំព័រ ១៣៩៤៦ (“នៅពាក់កណ្តាលឆ្នាំ១៩៧៨ ខៀវ សំផន បានធ្វើជាអធិបតីក្នុងកិច្ចប្រជុំអប់រំនយោបាយនៅបុរីកីឡា ជាកន្លែងដែលគាត់បានប្រកាសនៅចំពោះមុខអ្នកចូលរួមពី ៤០០ ទៅ ៥០០ នាក់ ថា ឈ្មោះ ឈឹម សំអោក *ហៅ* ប៉ង់ នៅមន្ទីរ ស-២១ ត្រូវបានចាប់ខ្លួន និងដកចេញ “ដោយសារតែគាត់ជាអ្នកចូលដៃក្បត់ជាមួយនឹង*យួន* និងបានណែនាំថា កុំឲ្យ “ធ្វើតាមអ្វីដែល ប៉ង់ បានធ្វើ”)។ *ប្រៀបធៀបជាមួយនឹង* ឯកសារ **E319/71.2.7** កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ឆ:៣៩-៤០ (និយាយពីចំនួនអ្នកចូលរួម), ឆ:៤៣-៤៤ (“កាលនុងគឺឆ្នាំ១៩៧៨ ហ្នឹងគាត់[ខៀវ សំផន] លើកឡើងពីភូមិភាគឧត្តរក្បត់ គឺពាក់ព័ន្ធដល់មន្ទីរ ៨៧០ ដល់ឈ្មោះ ប៉ង់ ហ្នឹង គាត់ថា ប៉ង់ ហ្នឹងក្បត់។ [...] គឺនៅក្នុងឆ្នាំ១៩៧៨ មុនឆ្នាំ១៩៧៩បន្តិច [ការឈ្លានពាន], ៤៥, ៤៧, ៥០, ៥៧។

[48] ខៀវ សំផន តវ៉ាថា ការពឹងផ្អែករបស់អង្គជំនុំជម្រះសាលាដំបូងលើសក្ខីកម្មរបស់ ឯក ហេន ដើម្បីធ្វើការសន្និដ្ឋានថា ខៀវ សំផន “បានចូលរួម និងបង្រៀនក្នុងវគ្គអប់រំ និងមិទ្ទីងមហាជន ដែលនៅពេលនោះ អំពើដែលត្រូវបានចាត់ទុកថាមានលក្ខណៈ

27. អង្គជំនុំជម្រះសាលាដំបូងបានសង្ខេប[49] ភស្តុតាងដែលបានបង្ហាញពីការដឹងឮរបស់ ខៀវ សំផន ស្តីពីគោលនយោបាយ គំរូនៃការប្រព្រឹត្ត និងឧក្រិដ្ឋកម្មជាក់លាក់ ដែលស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង០០២/០២ ដោយបានរៀបចំជាបីប្រភេទ៖ (i) ភស្តុតាងដែលបង្ហាញថា ខៀវ សំផន បានដឹងឮពីលទ្ធភាពដែលថាឧក្រិដ្ឋកម្ម *នឹងត្រូវបាន* ប្រព្រឹត្ត[50] (ii) ភស្តុតាងដែលបង្ហាញថាគាត់បានដឹងឮពីឧក្រិដ្ឋកម្មនានា *នៅពេលនោះ* ដែលត្រូវបានប្រព្រឹត្ត[51] និង (iii) ភស្តុតាង ដែលបង្ហាញពីការដឹងឮពី

---

ឧក្រិដ្ឋប្រឆាំងទៅលើខ្មាំង ប.ក.ក ត្រូវបានយកទៅបិភាក្សា លើកទឹកចិត្ត និងញុះញង់ រួមទាំងប្រឆាំងនឹងជនជាតិវៀតណាម អតីតរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងពួកផ្តាច់ខ្លួននៅក្នុងជួរបដិវត្តន៍ដទៃទៀត" គឺមានលក្ខណៈ "ទូលំទូលាយ និងទៅពេក ធ្វើឲ្យពិបាកកំណត់ប្រភព"។ ទោះបីជាការលំបាកបែបនេះនេះក្តី គាត់សន្និដ្ឋានថា "ឃើញច្បាស់ថា ឯក ហេន គឺជាប្រភពដ៏សំខាន់ សម្រាប់គាំទ្រដល់ការអះអាងនេះ" អះអាងថាការរកឃើញផ្នែកអង្គហេតុនេះសំខាន់សម្រាប់សម្អាងហេតុរបស់អង្គជំនុំជម្រះ និងបង្ហាញឲ្យឃើញថា ការរកឃើញរបស់អង្គជំនុំជម្រះដែលថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មក្រោយពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត តាមវិធីណាមួយអាស្រ័យលើភស្តុតាងរបស់គាត់។ *សូមមើល* ឯកសារ **F51** សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ៣៦-៣៨។ ឯកសារ **E465** សំណុំរឿង០០២/០២ សាលក្រម កថាខណ្ឌ ៤២៥៣។

[49] នៅក្នុងឯកសារ **F51** សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ៣៧ ខៀវ សំផន តវ៉ាអំពីចំនួននៃការយោងនឹងយោងផ្សេងទៀតទៅនឹងកថាខណ្ឌផ្សេងៗ។ ការអនុវត្តនេះគឺគ្រាន់តែបញ្ជាក់ពីសាលក្រមដ៏វែង និងកិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលក្រមនៅក្នុងទ្រង់ដែលបានរៀបចំមួយ ដែលចៀសវាងការនិយាយច្រំដែល។

[50] ឯកសារ **E465** សាលក្រមលើសំណុំរឿង០០២/០២ កថាខណ្ឌ ៤២០៦-៤២០៨។ អង្គជំនុំជម្រះពឹងផ្អែកលើ *ក្នុងចំណោមនោះ* ភស្តុតាងពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានធ្វើផែនការ បានសាកល្បង និង បានអនុវត្តនៅក្នុង "តំបន់រំដោះ" បន្ទាប់ពី ខៀវ សំផន បានចូលរួមនៅក្នុង ប.ក.ក រួមទាំងការសម្លាប់អ្នកនយោបាយប្រឆាំង ការបោសសំអាតនៅក្នុងជួរបក្ស ការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃព្រះពុទ្ធសាសនា ការរៀចចំអាពាហ៍ពិពាហ៍ និង ព្រឹត្តិការណ៍នានា ដែលនៅក្នុងនោះពួកអ្នកដែលចូលរួមជាមួយនឹងវៀតណាមត្រូវបានដកចេញយកទៅសម្លាប់ចោល។ គេកត់សម្គាល់គោលជំហររបស់ ខៀវ សំផន អំពីសារៈសំខាន់ ការចូលរួមនៅក្នុងការប្រជុំនានានៃគណៈអចិន្ត្រៃយ៍ ដែលនៅក្នុងនោះរឿងសំខាន់ៗត្រូវបានពិភាក្សា និងសេចក្តីសម្រេចចាំបាច់នានាត្រូវបានធ្វើឡើង ហើយសេចក្តីថ្លែងការណ៍ជាបុគ្គលដែលគាត់ និងមេដឹកនាំផ្សេងៗទៀតបានធ្វើឡើង (ហើយចំពោះពួកវានេះហើយដែលគាត់មានសិទ្ធិពិសេស) ដែលនៅក្នុងនោះការអនុវត្តពីគោលនយោបាយឧក្រិដ្ឋនានាត្រូវបានពិភាក្សា។

[51] ឯកសារ **E465** សាលក្រមលើសំណុំរឿង០០២/០២ កថាខណ្ឌ ៤២០៩-៤២៤៩។ អង្គជំនុំជម្រះបានពឹងផ្អែកលើ *ក្នុងចំណោមនោះ* ភស្តុតាងស្តីពីការចូលរួមរបស់ ខៀវ សំផន និងការចូលរួមចំណែកនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍, ទំនាក់ទំនងដ៏ជិតស្និទ្ធរបស់គាត់ជាមួយនឹង និងភាពជិតបំផុតទៅនឹង ប៉ុល ពត និង នួន ជា, អង្គហេតុដែលថាការបោសសំអាតជាទ្រង់ទ្រាយធំនៃកម្មាភិបាលពាណិជ្ជកម្មដែលបានចាប់ផ្តើម និងបានបន្តបានយ៉ាងល្អប្រសើ នៅក្នុងការកាន់កាប់របស់គាត់ក្នុងឋានៈជាអ្នកមើលការខុសត្រូវលើកិច្ចការរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, ភស្តុតាងដែលថាគាត់ជាអ្នកដែលត្រូវបានទុកចិត្តពោះការធ្វើការស៊ើបអង្កេតដ៏ប្រណិតចូលទៅក្នុង ថាតើ ឬ មិនមែនទេ ដែលមន្ត្រីផ្លូវការជាក់លាក់គឺជាខ្មាំង, ភស្តុតាងនៃសេចក្តីថ្លែងការណ៍ជាសាធារណៈ ដែលនៅក្នុងនោះគាត់បានដកចេញនូវពួកវៀតណាមសម្រាប់ប្រព្រឹត្តកម្មដែលរើសអើង, ហើយនិងភស្តុតាងស្តីពី

ឧក្រិដ្ឋកម្មរបស់គាត់បានកើតឡើង *នៅក្រោយពេល* ដែលត្រូវបាប្រព្រឹត្ត[52]។ វាគឺនៅក្នុងប្រភេទទីបី ដែលភស្តុតាងនៅបូរីកីឡារបស់ ឯក ហេន ត្រូវបានយោង[53] ក៏ប៉ុន្តែ សំខាន់ក្នុងការយល់ដឹងថា វាជាផ្នែកមួយនៃភស្តុតាងដ៏ច្រើនសន្ធឹកដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណា នៅមុនពេលសន្និដ្ឋានថា ខៀវ សំផន មានការដឹងឮជាចាំបាច់ពីទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ។

28. ជារួម ក្នុងបរិបទភស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងឮរបស់ ខៀវ សំផន មិនមានលទ្ធភាពពិតប្រាកដ ដែលថា ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ឯក ហេន អំពីការប្រជុំនៅបុរីកីឡា ត្រូវបានដាក់នៅចំពោះមុខខ្លួនផងដែរនោះ អង្គជំនុំជម្រះអាចចេញសាលក្រមផ្សេងទាំងស្រុង ឬដោយផ្នែកនោះឡើយ។ ជាការពិតដូចគ្នាដែរសម្រាប់ការរកឃើញដ៏ទូលំទូលាយជាងនេះ ដូចជាចេនារបស់គាត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស[54] និងការចូលរួមចំណែករបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម[55]។

## ២. ជួន ធី

ការឡើងថ្នាក់ផ្ទាល់ខ្លួនរបស់គាត់នៃគោលនយោបាយរបស់បក្ស ចំពោះការកើនឡើងយ៉ាងឆាប់រហ័សនៃប្រជាជនកម្ពុជាប្រជាធិបតេយ្យ។

[52] ឯកសារ E465 សាលក្រមលើសំណុំរឿង០០២/០២ កថាខណ្ឌ ៤២៥០-៤២៥៤។ ជាការបន្ថែមទៅនឹងភស្តុតាងនៅបុរីកីឡា អង្គជំនុំជម្រះបានពឹងផ្អែកលើ *ក្នុងចំណោមនោះ* លិខិតមួយក្នុងឆ្នាំ១៩៧៧ ពីអង្គការលើកលែងទោសអន្តរជាតិ ដែលបានបញ្ជាក់ពីការខ្វល់ខ្វាយទៅនឹងរបាយការណ៍នានាស្តីពីការសម្លាប់យ៉ាងរង្គាល និងការធ្វើបាបប្រជាជនស៊ីវិល។ លិខិតមួយក្នុងឆ្នាំ១៩៧៨ ពីអង្គការលើកលែងទោសអន្តរជាតិ និងគណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប ដែលបានពិនិត្យឡើងវិញនូវការអំពាវនាវរបស់អង្គការលើកលែងទោសអន្តរជាតិនាឆ្នាំ១៩៧៧។ បទសម្ភាសន៍របស់ ខៀវ សំផន សេចក្តីថ្លែងការណ៍ និងការបោះពុម្ពផ្សាយនានា ដែលបានបង្ហាញពីការដឹងឮសហកាលរបស់គាត់ពីឧក្រិដ្ឋកម្ម ជាពិសេសទាក់ទងទៅនឹងការបោសសំអាតផ្ទៃក្នុង និងការបង្កើត និងប្រតិបត្តិការរបស់សហករណ៍ និងការដ្ឋាន។ បទសម្ភាសផ្ទាល់ខ្លួនបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលនៅក្នុងនោះ ខៀវ សំផន បានដឹងឮពីការស្លាប់របស់ភ្នាក់ងារវៀតណាមដែលបានលើកឡើងចោទប្រកាន់, ពួកអ្នករៀបចំរដ្ឋប្រហារ និងប្រជាជនស៊ីវិលស្លូតត្រង់។ ការអាចចូលមើលបានរបស់ ខៀវ សំផន ចំពោះសារាចរនានារបស់ ប.ក.ក, ឯកសារ គោលនយោបាយ, សុន្ទរកថា និងការបោះពុម្ពផ្សាយពីកិច្ចពិភាក្សាស្តីពីការអនុវត្តគោលនយោបាយផ្សេងៗរបស់ ប.ក.ក។ ហើយនិងលិខិតនានាដែលគាត់បានទទួលក្នុងឋានៈជាប្រធានរដ្ឋដែលមានតែឈ្មោះ ដោយបានកត់សម្គាល់ពីរបាយការណ៍នានា ស្តីពីអំពើឃោរឃៅប្រឆាំងនឹងអតីតទាហាន និងមន្ត្រីនៃរបបសាធារណៈរដ្ឋខ្មែរ។

[53] ឯកសារ E465 សំណុំរឿង០០២/០២ សាលក្រម ជើងទំព័រ ១៣៨៧៣ បានយោងទៅលើកថាខណ្ឌ ៤២៧១-៤២៧៣ ដែលក្នុងនោះ ជាថ្មីម្តងទៀត ភស្តុតាងរបស់ ឯក ហេន គ្រាន់តែជាផ្នែកមួយ។

[54] *ផ្ទុយពី* ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ១៨-២៩។

[55] *ផ្ទុយពី* ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ៣០-៣៥។

29. កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ខកខានមិនបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបានតាមវិធាន ៨៧(៣) និង ១០៨(៧)ទេ។ កំណត់ហេតុស្តាប់ចម្លើយថ្មីមិនគួរត្រូវបានអនុញ្ញាតទទួលយកទេ ដោយសារតែវាជាភស្តុតាងច្រំដែល ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណារួចហើយ និងហេតុដូច្នេះមិនអាចជាកត្តាកំណត់ក្នុងការផ្តន្ទាទោស ខៀវ សំផន ឡើយ។

## *ក. កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី គឺជាភស្តុតាងច្រំដែល ដែលអង្គជំនុំជម្រះបានពិចារណារួចហើយ*

30. ខៀវ សំផន អះអាងថា ផ្នែកជាច្រើននៃកំណត់ហេតុស្តាប់ចម្លើយ ជួន ធី មានភាពផ្ទុយគ្នា ឬមានមន្ទិលសង្ស័យលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ[56]។ គាត់បានតវ៉ាជាដដែលៗថា អង្គជំនុំជម្រះសាលាដំបូង បានមើលរំលងភស្តុតាងរបស់ ជួន ធី និងសាក្សីផ្សេងទៀត ដោយបានអះអាងថាកំណត់ហេតុស្តាប់ចម្លើយថ្មីបញ្ជាក់ភស្តុតាងដែលថាអង្គជំនុំជម្រះបានមើលរំលង[57]។ ខណៈដែលតវ៉ាអំពីការទទួលយករបស់អង្គជំនុំជម្រះលើភស្តុតាង ដែលត្រូវបានអនុញ្ញាតទទួលយកថាគួរតែត្រូវបានបដិសេធ ដោយសារ ភស្តុតាងហួសពីវិសាលភាពនៃសំណើសុំភស្តុតាងបន្ថែមនោះ ទោះជាយ៉ាងណាពួកគេបង្ហាញថា កំណត់ហេតុស្តាប់ចម្លើយថ្មី គឺជាភស្តុតាងមានលក្ខណៈច្រំដែលយ៉ាងខ្លាំង ដែលអង្គជំនុំជម្រះមានកាតព្វកិច្ច ត្រូវពិចារណាក្នុងការចេញសាលក្រមរបស់ខ្លួន។ អនុលោមតាមវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង ដែលជាផ្នែកមួយនៃលក្ខណៈវិនិច្ឆ័យសម្រាប់ការអនុញ្ញាតទទួលយកភស្តុតាងបន្ថែម តាមវិធាន ១០៨(៧) ភស្តុតាងដែលច្រំដែលអាចត្រូវបានបដិសេធ។

31. កំណត់ហេតុស្តាប់ចម្លើយថ្មី លើកឡើងថា គូស្រករនៅក្នុងកងរបស់ ជួន ធី មិនត្រូវបានផ្គូរផ្គងតាមវណ្ណៈនោះទេ ហើយមានសេរីភាពជ្រើសរើសដៃគូរបស់ពួកគេ[58]។ ចម្លើយនេះច្រំដែលខ្លាំងនៃកំណត់ហេតុស្តាប់ចម្លើយពីមុន និងសក្ខីកម្មរបស់ ជួន ធី[59] ក៏ដូចជាភស្តុតាងរបស់ ឯក ហឿន និង

[56] *សូមមើ ឧទាហរណ៍* ឯកសារ **F51** សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ៦០, ៦៤, ៦៦, ៦៩, ៧១, ៧៣។

[57] *សូមមើ ឧទាហរណ៍* ឯកសារ **F51** សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ៥៧, ៦៤, ៦៦, ៦៧-៧១, ៧៣។

[58] ឯកសារ **F51** សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ៥៩។

[59] ឯកសារ **E3/10713** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.២៤, ២៩, ៣១ (“សៈ ពេលនោះ ប៉ុល ពត មានបានលើកឡើងថា ប្រជាជនប្រភេទណារៀបការជាមួយប្រភេទនាដែរទេ? ឆៈ ខ្ញុំចង់ប្រាប់ថា សម្រាប់អង្គភាពខ្ញុំគឺមិនដែលមាននិយាយអំពីប្រភេទប្រជាជនខុសគ្នាអីទេ តែចំណែកអង្គភាពផ្សេង ខ្ញុំមិនដឹងទេ។”) ៣៣។ ឯកសារ **E1/183.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ម៉ោង 09.59.13-10.01.15 (“កន្លែងគេត្រូវស្នើ ឬក៏ការពេញចិត្តរបស់ផងខ្លួនក៏ស្នើ”)។ ឯកសារ **E1/489.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.56.58-15.59.10 (“ទំនាក់ទំនងជាមួយគ្នារវាងយុវជន យុវនារីពេល

ស៊ូ សឿន ដែលត្រូវបានអនុញ្ញាតទទួលយក[60]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងបែបនេះ បានធ្វើការយោងយ៉ាងច្បាស់លាស់ទៅកាន់សក្ខីកម្មរបស់ ស៊ូ សឿន[61] ក៏ដូចជាភស្តុតាងរបស់ ឌុច ថា "ក្នុងបញ្ហាជ្រើសរើសគូស្រករ គេមិនអាចហាមដាច់ខាតទេ"[62]។ ចៅក្រមក៏បានពិចារណាលើភស្តុតាងដែលថា យុទ្ធជន និងកម្មាភិបាល ជាញឹកញាប់ ទទួលបានបុព្វសិទ្ធិទាក់ទងនឹងការជ្រើសរើសអ្នកដែលខ្លួនរៀបការ[63] ហើយបុគ្គលខ្លះត្រូវបានអនុញ្ញាតឱ្យដាក់ឈ្មោះអ្នកដែលពួកគេចង់រៀបការជាមួយ ទៅកាន់ថ្នាក់លើរបស់ខ្លួន ឬអ្នកគ្រប់គ្រងខ្លួនដើម្បីសុំការអនុញ្ញាត[64]។ កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី គ្រាន់តែបញ្ជាក់បន្ថែមចំណុចទាំងអស់នេះ ដោយមានចំណុចជាក់លាក់ជារឿងខ្លីៗ។

32. កំណត់ហេតុស្តាប់ចម្លើយថ្មីក៏លើកឡើងថា មនុស្សនៅក្នុងកងរបស់ ជួន ធី បានរៀបការតាមឆន្ទៈរបស់ពួកគេ និងមានលទ្ធភាពបដិសេធអាពាហ៍ពិពាហ៍ដោយគ្មានផលប៉ះពាល់អ្វីឡើយ[65]។ ការណ៍នេះក៏ជាភស្តុតាងច្រំដែលផងដែរ ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង រួមទាំងចម្លើយផ្ទាល់ពីមុនរបស់ ជួន ធី ផង[66]។ ជាងនេះទៀត សាលក្រមបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះមានការ

---

នោះ គ៏មិនមានសភាពណាតឹងរ៉ឹងដែរ ដូច្នេះការជួបគ្នា ធ្វើការងារគ្នាបាន ដូច្នេះអាចប្រាស្រ័យទាក់ទងគ្នា រហូតដល់មានចងមេត្រីស្នេហានឹងគ្នាទៅហើយស្នើទៅប្រាប់មេថា ខ្ញុំស្រឡាញ់នាងនោះ ហើយនាងនោះ ដោយស្នើទៅ គេយល់ព្រម អាហ្នឹងគេនេះទៅមានអី អត់មានការបង្ខិតបង្ខំទេ។")។ ឯកសារ **E1/490.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.08.25-09.09.45។

[60] ឯកសារ **E1/299.1** ប្រតិចារឹក ឯក ហឿន ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.11.31-15.13.55 ("ចំពោះប្រជាជនចាស់ប្រជាជនថ្មីហ្នឹង ដូចអត់ដែលឮ ក្នុងស្រុកក្នុងឃុំអត់ដែលមានលើករឿងហ្នឹងនិយាយ ឃើញតែរៀបការចាស់យកថ្មីយកចាស់ដូចធម្មតាអ៊ីចឹង។ អត់ដែលមានឯកសារនិយាយអីទេ ឃើញតែរៀបទៅមកទៅអ៊ីចឹង។")។ ឯកសារ **E1/310.1** ប្រតិចារឹក ស៊ូ សឿន ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 15.20.56-15.22.58 ("ស៖ អ៊ីចឹងនៅសម័យនោះ តើគេអនុញ្ញាតឱ្យរៀបការរវាងអ្នកមូលដ្ឋាន និងអ្នកថ្មីដែរឬទេ? ឆ៖ ចាស កន្លែងខ្លះក៏ ខ្ញុំនិយាយតែកន្លែងខ្លះ គឺស្រុកខ្ញុំវាមានខ្លះដែរ។ ការពាក់ព័ន្ធជាមួយគ្នា ដែលបានរៀបចំ ដូចស្នើទៅតាមសង្កាត់ សង្កាត់ឡើងមកស្រុកអ៊ីចឹងទៅ ហើយសម្រេចថា មនុស្សល្អ យើងរៀបចំឱ្យ។")។

[61] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥៧៨ *ដកស្រង់* ឯកសារ **E1/310.1** ប្រតិចារឹក ស៊ូ សឿន ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 15.20.56-15.22.58។

[62] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥៧៧។

[63] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥៩១។

[64] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥៩៩-៣៦០០, ៣៦០២។

[65] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៦២ (ស្ត្រីដែលត្រូវបានរៀបចំឱ្យរៀបការជាមួយកងទ័ពពិការមានសិទ្ធិបដិសេធការរៀបការដោយមិនមានផលវិបាកអ្វីឡើយ)។ *សូមមើលផងដែរ* កថាខណ្ឌ ៦៤, ៦៦-៦៧, ៦៩-៧០។

[66] ឯកសារ **E1/183.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ម៉ោង 09.59.13-10.03.02 ("ដូច្នេះកន្លែងគេត្រូវស្នើ ឬក៏ការពេញចិត្តរបស់ផងខ្លួនក៏ស្នើ។ [...] គឺគ្មាននរណាបង្ខំទេ។ [...] មិនមែនដោយចាប់បង្ខំទេ គឺដោយស្ម័គ្រចិត្តទាំងសងខាង

ប្រុងប្រយ័ត្នចំពោះគោលនយោបាយផ្លូវការរបស់ ប.ក.ក ដែលតម្រូវឱ្យមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរ និងបានពិចារណាលើសក្ខីកម្មរបស់កម្មាភិបាល ប.ក.ក ជាច្រើន ដែលបាននិយាយថាការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងផ្អែកតាមការព្រមព្រៀងរបស់បុគ្គលទាំងនោះ[67]។ ចៅក្រម បានវាយតម្លៃចម្លើយទាំងអស់នេះយ៉ាងប្រុងប្រយ័ត្ន រួមទាំងសក្ខីកម្មរបស់ រៀល សន, ឱ ហូ, ពេជ្រ ជឹម និង មាស វឿន[68]។ ពួកគាត់ក៏បានយោងសម្អាងភស្តុតាងរបស់ ឯម ភឿង និង សុន វុត ផងដែរ ដែលបានបដិសេធការរៀបអាពាហ៍ពិពាហ៍ ដោយមិនមានផលប៉ះពាល់អវិជ្ជមាន[69]។ កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី មិនបានបន្ថែមអ្វីសំខាន់សម្រាប់អង្គជំនុំជម្រះធ្វើការពិចារណាពាក់ព័ន្ធនឹងបញ្ហានេះទេ។

33. ជាចុងក្រោយ ខៀវ សំផន អះអាងថា កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី បំពេញបន្ថែមភស្តុតាងពីមុនរបស់គាត់ ដែលថាគូស្រករនៅក្នុងកងរបស់គាត់ មិនត្រូវបានតាមដានដើម្បីបញ្ជាក់ថាតើពួកគេរួមសង្វាសអាពាហ៍ពិពាហ៍របស់ខ្លួន ឬយ៉ាងណា[70]។ ការលើកឡើងនេះមិនគួរឱ្យជឿជាក់ទេ ដោយសារតែវាជាន់គ្នាយ៉ាងខ្លាំងទៅនឹងសក្ខីកម្មសវនាការរបស់ ជួន ធី។ ព័ត៌មានលម្អិតរបស់កំណត់ហេតុស្តាប់ចម្លើយថ្មីទាក់ទងនឹបទពិសោធន៍ផ្ទាល់ខ្លួនរបស់ ជួន ធី ត្រូវបានគេដឹងថាមាននៅក្នុងចម្លើយដ៏ទូលំទូលាយជាងនេះរបស់គាត់ដែលថា គូស្រករនៅក្នុងកងរបស់គាត់មិនត្រូវបាន

---

ឬក៏យុទ្ធជន មហាជនហ្នឹង គេឱ្យអ្នកដឹកនាំហ្នឹងរើសឱ្យគេ គេរៀបចំឱ្យ គេធ្វើតាម គេឱ្យអ្នកគឺយកង្នកហ្នឹង គឺអ៊ីចឹង គេធ្វើពេលហ្នឹង គឺអ៊ីចឹង គឺអង្គភាពខ្ញុំគឺមានស្ដែងៗអ៊ីចឹង។ គឺអត់មានអ្នកណាចាប់បង្ខំឱ្យយកទេ អត់ទេ គឺស្ម័គ្រចិត្តតែម្តង។")។ ឯកសារ **E1/489.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.56.58-15.59.10។ ឯកសារ **E1/490.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.08.25-09.11.42, 09.18.04-09.19.33 ("ឯបើសិនជារៀបចំទៅ ពេលដែលរៀបចំអ្នកដែលគេចាប់ទៅ ចេះតែដាក់ទៅវាច្រឡំ ដែលមិនពេញ សាម៉ីខ្លួនខាងប្រុសក៏ដោយ ខាងស្រីក៏ដោយដែលគេមិនពេញចិត្តគេអាចដើរចេញមិនរៀបចំបាន។") ម៉ោង 09.21.23-09.22.30 ("គ្រាន់តែឮគេនិយាយថា មានអង្គភាពខ្លះដែលរៀបចំដោយចាប់បង្ខំ ដល់នេះសាម៉ីខ្លួនគេអត់ត្រូវ គេអត់ព្រមយកហ្នឹង គឺខ្ញុំសួរថាគេធ្វើម៉េចដែរ អាហ្នឹងគេទៅកន្លែងគេទៅ អត់មានដឹងគេធ្វើម៉េច អត់មានដឹងផង គ្រាន់តែឮគេថាដែរហ្នឹង។")។ ឯកសារ **E3/10713** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.២២, ២៩, ៤៣។

[67] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៦១៧, ៣៦២៣។ ខៀវ សំផន ថែមទាំងទទួលស្គាល់ថាអង្គជំនុំជម្រះបាន "បង្ខំចិត្ត" កំណត់អត្តសញ្ញាណសាក្សីទាំងអស់នេះ និងសក្ខីកម្មរបស់ពួកគេ (*សូមមើល* ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៦៦)។ ទោះជាយ៉ាងណា ទស្សនៈរបស់គាត់ដែលថាអង្គជំនុំជម្រះសាលាដំបូង "មិនបានទាញផលវិបាកចេញពីសក្ខីកម្មទាំងនេះ" គឺហួសពីវិសាលភាពនៃសំណើសុំភស្តុតាងបន្ថែម ហើយស័ក្តិសមជាងសម្រាប់បណ្តឹងសាទុក្ខ។

[68] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម ៣៦១៧។

[69] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៦២៥។

[70] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៧១-៧២។

តាមដានទេ[71]។ វាក៏ជាភស្តុតាងច្រំដែលដែលត្រូវបានផ្តល់ដោយអតីតកម្មាភិបាល ដែលបានផ្តល់សក្ខីកម្មថា ការតាមដានមិនកើតមាននៅក្នុងតំបន់ជាក់លាក់របស់ពួកគេទេ[72]។

34. សរុបមក ទោះបីជាកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី អាចតវ៉ាថាមាន "ព័ត៌មានលម្អិតសំខាន់ជាងអំពីការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍" ជាងភស្តុតាងដែលត្រូវបានអនុញ្ញាតទទួលយកពីមុនរបស់គាត់[73] ក៏ព័ត៌មានបន្ថែមទាំងនេះភាគច្រើនជារឿងរ៉ាវខ្លីៗ និងដូចគ្នាខ្លាំងទៅនឹងភស្តុតាងដទៃទៀត ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។

## *ខ. កំណត់ហេតុស្តាប់ចម្លើយថ្មីច្រំដែលរបស់ ជួន ធី មិនអាចជាកត្តាកំណត់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះទេ*

35. ដោយសារតែកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី គឺជាភស្តុតាងដែលច្រំដែលខ្លាំង ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណារួចហើយនោះ មិនមានលទ្ធភាពពិតប្រាកដណាមួយដែលថា កំណត់ហេតុស្តាប់ចម្លើយនេះអាចនាំឱ្យអង្គជំនុំជម្រះចេញសាលក្រមផ្សេងទាំងស្រុង ឬដោយផ្នែកនោះទេ ប្រសិនបើវាត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ។ ដោយសារលទ្ធភាពបែបនេះតម្រូវឱ្យមានការអនុញ្ញាតទទួលយកភស្តុតាងបន្ថែមស្របតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី មិនគួរត្រូវបានទទួលយកឡើយ។

36. ឧទាហរណ៍ ខៀវ សំផន អះអាងថា កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី គួរតែត្រូវបានអនុញ្ញាតទទួលយក ដោយសារតែវាផ្ទុយទាំងស្រុងទៅនឹងការរកឃើញរបស់អង្គជំនុំជម្រះ លើការផ្សំផ្គុំគូស្រករតាមវណ្ណៈ[74]។ គាត់អះអាងថា ប្រសិនបើភស្តុតាងដែល "នៅក្នុងជួរកងទ័ពគេអត់បែង

---

[71] ឯកសារ **E1/490.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.13.05-09.15.00 ("ពេលដែលរៀបការហើយ មិនឱ្យទៅតាមដានរឿងដំណេកអីជាមួយគ្នា គឺអត់ដែលឮ។ អត់មានដែលឪអ្នកខាងលើឱ្យតាមដានទេ ខ្ញុំអត់ដែលក្តាប់បាន អត់ដែលឮសោះ តាំងពីធ្វើមេដឹកនាំដែរ ខ្ញុំក្តាប់អង្គភាពហ្នឹង អត់ដែលឮទេ។ គ្រាន់តែអាហ្នឹង គឺសូមបញ្ជាក់ប៉ុណ្ណឹង។")។

[72] *សូមមើលឧទាហរណ៍* ឯកសារ **E1/274.1** ប្រតិចារឹក នាង អ៊ួច ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ម៉ោង 10.45.57-10.51.22។ ឯកសារ **E1/291.1** ប្រតិចារឹក ពេជ្រ ជឹម ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ម៉ោង 09.25.02-09.26.58។ ឯកសារ **E1/296.1** ប្រតិចារឹក ខឹម ហឿន ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 16.05.03-16.07.53។

[73] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៧៥។

[74] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៥៩។ *សូមមើលផងដែរ* កថាខណ្ឌ ៥៨ *ដកស្រង់* ការរកឃើញដែលថា កំណត់ហេតុស្តាប់ចម្លើយផ្ទុយគ្នាដូចដែលគេបានចោទឡើង៖ "អង្គជំនុំជម្រះជឿជាក់ថា ប្រវត្តិរូបរបស់បុគ្គលត្រូវបានពិនិត្យ មុននឹងផ្សំផ្គុំពួកគេឱ្យរៀបការ" (*សូមមើល* ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥៧៦) "ជាទូទៅប្រជាជនដែលមានប្រវត្តិស្រដៀងគ្នាត្រូវបានផ្សំផ្គុំឱ្យរៀបការជាមួយគ្នា" ហើយ "ប្រជាជនដែលមានប្រវត្តិផ្សេងគ្នាក៏

ចែកប្រជាជនតាមវណ្ណៈ” ហើយ “អ្នកណាក៏ដោយមានសិទ្ធិជ្រើសរើសគូស្រករ” ត្រូវបានពិចារណា នោះ “អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានការអនុវត្តដូចៗគ្នានៅទូទាំងប្រទេស និងមានគោល នយោបាយថ្នាក់ជាតិដែលបក្សបានអនុម័ត ដូចខ្លួនបារៀបរាប់ទេ”[75]។ ទីមួយ ខៀវ សំផន បាន បំផ្លើសភស្តុតាងរបស់ ជួន ធី។ នៅពេលដែលវាយតម្លៃឱ្យបានត្រឹមត្រូវទាំងមូល ជួន ធី បានអះអាង យ៉ាងស៊ីចង្វាក់ថា គាត់គ្រាន់តែបានដឹងពីអ្វីដែលបានកើតឡើងនៅក្នុងកងរបស់គាត់តែប៉ុណ្ណោះ មិន មែននៅក្នុងកងផ្សេងទៀតទេ និងពិតជាមិនមែនកងទ័ពទាំងមូល ដូចដែល ខៀវ សំផន បានលើកឡើង នោះទេ[76]។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងមិនដែលបានសន្និដ្ឋានថា មាន “ការអនុវត្តដូចៗគ្នានៅ ទូទាំងប្រទេស” ដើម្បីផ្សំផ្គុំតាមវណ្ណៈនោះទេ[77]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានខុស គ្នាថា “ជាទូទៅ ប្រជាជនដែលមានប្រវត្តិស្រដៀងគ្នា ត្រូវបានផ្សំផ្គុំឱ្យរៀបការ”[78]។ ការប្រើពាក្យ “ជាទូទៅ” បញ្ជាក់ថា ចៅក្រមបានដឹងអំពីករណីលើកលែង ដែលរឿងនេះមិនបានកើតឡើង ស្រដៀងគ្នាទៅនឹងស្ថានភាពដែលបានរៀបរាប់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី និង ភស្តុតាងដែលត្រូវបានអនុញ្ញាតទទួលយកដែលត្រូវបានពិភាក្សាខាងលើឡើយ[79]។ ដោយសារតែ កំណត់ហេតុស្តាប់ចម្លើយថ្មី ពិតជាស្របគ្នាទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនោះ

---

ត្រូវបានអនុញ្ញាតិឱ្យរៀបការជាមួយគ្នាដែរ ប្រសិនបើអាជ្ញាធរយល់ថាពួកគេជា “ប្រជាជនល្អ”” (*សូមមើល* ឯកសារ **E465** សំណុំរឿង០០២/០២ សាលក្រម កថាខណ្ឌ ៣៥៨០)។

[75] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៥៩-៦០។

[76] *សូមមើល ឧទាហរណ៍* ឯកសារ **E3/10713** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.២២, ៣១ (“សៈ ពេលនោះ ប៉ុល ពត មានបានលើកឡើងថា ប្រជាជនប្រភេទណារៀបការជាមួយប្រភេទនាដែរទេ? ឆៈ ខ្ញុំចង់ប្រាប់ថា សម្រាប់អង្គភាពខ្ញុំគឺមិនដែល មាននិយាយអំពីប្រភេទប្រជាជនខុសគ្នាអីទេ តែចំណែកអង្គភាពផ្សេង ខ្ញុំមិនដឹងទេ។”) ៤៣។ ឯកសារ **E319/71.2.4** កំណត់ ហេតុស្តាប់ចម្លើយ ជួន ធី ឆ.១៩។ ឯកសារ **E1/490.1** ប្រតិចារឹក ជួន ធី ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.11.42-09.13.05 (អំពី ថាតើការរៀបការត្រូវបានបង្ខំឬទេៈ “ខ្ញុំនិយាយពីលើកមុន ខ្ញុំថាសម្រាប់អង្គភាព អ្នកដែលអង្គភាពផ្សេងអាហ្នឹង ខ្ញុំមិនដឹងទេ”) ម៉ោង 09.13.05-09.15.00 (អំពីការតាមដានៈ “គ្រាន់តែអាហ្នឹង គឺសូមបញ្ជាក់ប៉ុណ្ណឹង។”) ម៉ោង 09.15.48-09.18.04 (អំពីៈ ការណែនាំឱ្យតាមដានៈ “អានេះបើខាងមូលដ្ឋាន ខ្ញុំក្តាប់មិនបានទេ ខ្ញុំជម្រាបអ៊ីចឹង ព្រោះខ្ញុំខាងអង្គភាពយោធា គឺខ្ញុំគ្រប់គ្រងនិងក្តាប់។ ខាងហ្នឹងគឺអត់មាន ដែលមានបញ្ហាអ៊ីចឹង [កើតឡើង] ផង។”)។

[77] *ផ្ទុយពី*ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៦០ ជើងទំព័រ ១១៧។ ខៀវ សំផន យោងទៅលើឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥៤៣ ប៉ុន្តែកថាខណ្ឌនេះពិភាក្សាអំពីបុគ្គលដែល “មានលទ្ធភាពស្មើទៅ កាន់ថ្នាក់លើរបស់ខ្លួន ដើម្បីសុំរៀបការជាមួយបុគ្គលណាម្នាក់ដែលខ្លួនពេញចិត្ត” ហើយ ប.ក.ក ណែនាំអំពីការជ្រើសរើស គូស្រករយ៉ាងប្រុងប្រយ័ត្ន។ វាមិនមានការសន្និដ្ឋានអំពីការអនុវត្តដូចគ្នានៃការផ្សំផ្គុំគូស្រករតាមវណ្ណៈទេ។

[78] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៥៨០ (គូសបញ្ជាក់បន្ថែម)។

[79] *សូមមើល* កថាខណ្ឌ ៣១ *យោងខាងលើ*។

មិនមានលទ្ធភាពប្រាកដប្រជាណាមួយដែលថា ប្រសិនបើវាត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង វាអាចនាំឱ្យអង្គជំនុំជម្រះនេះចេញសាលក្រមខុសពីនេះនោះឡើយ។

37. ទាក់ទងនឹងបញ្ហាព្រមព្រៀង ខៀវ សំផន អះអាងថា ភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់បុគ្គលនានានៅក្នុងកងរបស់ ជួន ធី ដែលបានរៀបការតាមឆន្ទៈរបស់ខ្លួន និងការបដិសេធរៀបអាពាហ៍ពិពាហ៍ដោយមិនមានផលវិបាកនោះ បញ្ជាក់ឱ្យឃើញថា "ប្រជាជនមិនត្រូវបានគេបង្ខំឱ្យរៀបការទេ និងយ៉ាងហោចណាស់ មិនមែនជាគោលនយោបាយដែលអនុម័តដោយ "ថ្នាក់ខ្ពស់បំផុតនៃ ប.ក.ក"" ដូចដែលអង្គជំនុំជម្រះបានសន្និដ្ឋាននោះទេ[80]។ ទោះជាយ៉ាងណា ខៀវ សំផន បកស្រាយខុសចំពោះការវាយតម្លៃអំពី ថាតើភស្តុតាងថ្មីរបស់ ជួ ធី អាចនាំឱ្យមានសាលក្រមផ្សេងឬយ៉ាងណា ដោយការយោងខុសទៅលើតែផ្នែកមួយនៃការសន្និដ្ឋានជាក់លាក់ ខណៈដែលមើលរំលងផ្នែកដែលផ្តល់ "តុល្យភាព" ដែលគាត់ចោទប្រកាន់ មិនមាននៅក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ[81]។ ជាពិសេស គាត់បានអះអាងថា "អង្គជំនុំជម្រះបានសន្និដ្ឋានថា បុគ្គល "ជាធម្មតាមិនបានទទួលការពិភាក្សាអំពីការរៀបការរបស់ខ្លួនទេ ហើយបានទទួលការជូនដំណឹងតែបន្តិចបន្តួច ឬអត់បានទទួលដំណឹងទាល់តែសោះថាពួកគេនឹងត្រូវរៀបការនោះ""[82]។ ការអះអាងនេះបានលុបបំបាត់ចោលផ្នែកសំខាន់ៗនៃការសន្និដ្ឋាន ដែលបញ្ជាក់ថា ការណ៍នេះមិនមែនជាការអនុវត្តដូចគ្នាយ៉ាងតឹងរឹងនោះទេ។ ការរកឃើញទាំងមូលលើកឡើងថា៖ "អង្គជំនុំជម្រះយល់ឃើញថា *ក្រៅពីបុគ្គលមួយចំនួនដែលត្រូវគេយកចិត្តទុកដាក់ជាង ដូចបានលើកឡើងខាងលើ* បុគ្គល *ដែលគេផ្សំផ្គុំឱ្យរៀបការ* ជាធម្មតាមិនបានទទួលការជូនដំណឹងតែបន្តិចបន្តួច ឬអត់បានទទួលដំណឹងទាល់តែសោះថាពួកគេនឹងត្រូវរៀបការនោះ"[83]។ ពាក្យថា "បុគ្គលដែលត្រូវគេយកចិត្តទុកដាក់ជាង" យោងត្រឡប់

---

[80] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៦២ (ស្ត្រីដែលត្រូវបានរៀបចំឱ្យរៀបការជាមួយកងទ័ពពិការមានសិទ្ធិបដិសេធអាពាហ៍ពិពាហ៍នោះដោយមិនមានផលវិបាក)។ *សូមមើលផងដែរ* កថាខណ្ឌ ៦៤, ៦៦-៦៧, ៦៩-៧០ ដែលតំណាងជាពិសេសសម្រាប់សេចក្តីអះអាងដូចគ្នានេះ។

[81] *សូមមើលឧទាហរណ៍* ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៦៤ (តវ៉ាថា ការពិចារណាអំពីកំណត់ហេតុស្តាប់ចម្លើយថ្មី "គួរណាធ្វើឱ្យអង្គជំនុំជម្រះសន្និដ្ឋានខុសពីមុន [...] អំពីការយល់ព្រមពីសាមីខ្លួនពាក់ព័ន្ធ") ៧០។

[82] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក កថាខណ្ឌ ៦៥។

[83] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៦១៦ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម កថាខណ្ឌ ៣៦២៣ ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "បុគ្គលមួយចំនួន ដូចជា យុទ្ធជន កម្មាភិបាល និងកងទ័ពពិការ" អាចត្រូវបានគេសួរយោបល់អំពីការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ ប៉ុន្តែនោះមិនមែនជាការអនុវត្តជាទូទៅនោះទេ។

ទៅផ្នែកនៃសាលក្រមដែលការផ្សំផ្គុំកងទ័ពពិការ យុទ្ធជន និងកម្មាភិបាលត្រូវបានពិភាក្សា[84]។ ជាក់ស្តែង ជួន ធី និងយុទ្ធជនគ្នាគាត់ អាចត្រូវបានចាត់ថ្នាក់ជា "បុគ្គលដែលត្រូវគេយកចិត្តទុកដាក់ជាង" ដែលទទួលបានការលើកលែងពីការសន្និដ្ឋាននេះ។ ហេតុដូច្នេះ មិនមានលទ្ធភាពពិតប្រាកដណាថា កំណត់ហេតុស្តាប់ចម្លើយថ្មី អាចនាំឲ្យអង្គជំនុំជម្រះផ្លាស់ប្តូរសេចក្តីសន្និដ្ឋានរបស់ខ្លួនទេ។

38. ដូចភស្តុតាងស្តីពីលក្ខខណ្ឌតម្រូវអំពីការព្រមព្រៀងនៃភាគីទាំងពីរ (រួមទាំងលទ្ធភាពក្លាយជាប្តីប្រពន្ធនឹងគ្នានៃទាហានពិការផង) និងការបដិសេធពុំព្រមរៀបការដោយគ្មានផលវិបាកនោះ កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី គឺជារឿងច្រំដែលនៃភស្តុតាងដែលបានទទួលរួចហើយ ដែលបានផ្តល់ដោយអតីតកម្មាភិបាល បកក ដែលនៅក្រោមគោលនយោបាយរបស់ បកក "គឺជាការចាំបាច់ដើម្បីឲ្យប្រាកដថាភាគីទាំងពីរបានយល់ព្រមជាមួយគ្នាដើម្បីរៀបការ និងគ្មានអ្វីនឹងកើតឡើងចំពោះពួកគេឡើយប្រសិនបើពួកគេបដិសេធពុំព្រមរៀបការជាមួយគ្នា"[85]។ នៅពេលអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃទៅលើភាពពេញលេញនៃភស្តុតាង អង្គជំនុំជម្រះនេះមានការយកចិត្តទុកដាក់ចំពោះភស្តុតាងដែលបានទទួលយករួចហើយនេះ និងបានកត់សម្គាល់ថា មានករណីលើកលែងមួយចំនួនដែរ ដែលការបដិសេធគ្មានផលវិបាក ប៉ុន្តែ *"មានករណីភាគច្រើនលើសលប់* បង្ហាញថា បុគ្គលមិនអាចបដិសេធមិនរៀបការដោយគ្មានផលវិបាកនោះឡើយ"[86]។ អង្គជំនុំជម្រះក៏បានទទួលស្គាល់ផងដែរថា មានករណីលើកលែងមួយចំនួនដែលមានបុគ្គលបានយល់ព្រមជាមួយគ្នាយ៉ាងពិតប្រាកដ ដូចបានបង្ហាញតាមរយៈការសម្រេចយ៉ាងដូច្នេះថា "ខណៈមាន *បុគ្គលខ្លះអាចបានយល់ព្រមជាមួយគ្នាយ៉ាងពិតប្រាកដ* ដើម្បីរៀបការជាមួយមនុស្សម្នាក់ទៀតដែលពួកគេបានជ្រើសរើស ឬបានស្នើដល់ពួកគេក៏ដោយ តែមានសាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំ បានផ្តល់សក្ខីកម្មថា ពួកគេគ្មានជម្រើស ឬសិទ្ធិដើម្បីបដិសេធឡើយ ហើយជឿថា ពួកគេត្រូវតែគោរពបញ្ជារបស់*អង្គការ*"[87]។ ដោយសារកំណត់ហេតុស្តាប់ចម្លើយសាក្សីថ្មីនេះ គឺជារឿងច្រំដែលនៃភស្តុតាងដែលបានទទួលយករួចហើយដែលធ្លាក់ចូលក្នុងករណីលើកលែងមួយ ឬទាំងពីរនៃករណីលើកលែងដែលបានកត់សម្គាល់ដោយអង្គជំនុំជម្រះ ហើយដែលត្រូវបានកម្រិតវិសាលភាពចំពោះតែការអនុវត្តក្នុងករណីនៃអង្គភាព

---

[84] *សូមមើល* **E465** សំណុំរឿង ០០២/០២ សាលក្រម ផ្នែក ១៤.៣.៤.៤ បុគ្គលដែលត្រូវគេយកចិត្តទុកដាក់ជាង ១៤.៣.៤.៤.១ កងទ័ពពិការ និង ១៤.៣.៤.៤.២ យុទ្ធជន និងកម្មាភិបាល។

[85] ឯកសារ **F51** សំណើសុំការអនុញ្ញាតឲ្យទទួលយក, កថាខណ្ឌ ៦៦, *យោង* ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម, កថាខណ្ឌ ៣៦១៧។ សូមមើលផងដែរ កថាខណ្ឌ ៣២ យោងខាងលើ។

[86] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម, កថាខណ្ឌ ៣៦២៥ (សង្កត់ន័យដើម)។

[87] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រម, កថាខណ្ឌ ៣៦១៩ (សង្កត់ន័យដើម)។

យោធារបស់ ជួន ធី[88]នោះ តែគេគ្មានលទ្ធភាពប្រាកដនិយមដែលអាចនឹងជំនះទៅលើភស្តុតាងដ៏ច្រើនលើសលប់ ដែលគាំទ្រចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី ការព្រមព្រៀងដែលអាចនឹងនាំឲ្យអង្គជំនុំជម្រះនេះផ្លាស់ប្តូរសាលក្រមរបស់ខ្លួននោះឡើយ។

39. ការសន្និដ្ឋានរបស់ ខៀវ សំផន ទាក់ទងនឹងការផ្តល់សិទ្ធិអំណាចក្នុងការរៀបការ គឺមានលក្ខណៈច្របូកច្របល់ ដោយសារការសម្រេចដែលគាត់យោង គឺទាក់ទងនឹងដំណើរការនៃការស្វែងរកការអនុញ្ញាតដើម្បីរៀបការពីអង្គការថ្នាក់ខ្ពស់ ប៉ុន្តែអំណះអំណាងរបស់គាត់ហាក់ដូចជាផ្តោតទៅលើសេរីភាពក្នុងការបដិសេធលើបញ្ជារបស់អង្គការណាមួយក្នុងការមិនរៀបការ និងបញ្ហានៃការព្រមព្រៀមគ្នា[89]។ ទោះក្នុងករណីណាក៏ដោយ កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី និយាយថា ពេលគាត់ និងប្រពន្ធរបស់គាត់ ចង់រៀបការ ពួកគេត្រូវធ្វើសំណើសុំទៅថ្នាក់លើសម្រាប់ការរៀបការរបស់ពួកគេ[90]។ កំណត់ហេតុនេះក៏និយាយផងដែរថា ពេលអ្នកសុំរៀបការចំនួន ១០គូ បានធ្វើសំណើទៅអង្គភាពរបស់ ជួន ធី ដើម្បីរៀបការនោះ គាត់ត្រូវបញ្ជូនសំណើទាំងនោះទៅថ្នាក់លើ[91]។ ភស្តុតាងនេះ មានសង្គតិភាពជាមួយនឹងការសម្រេចអំពីសិទ្ធិអំណាចដែលបានកំណត់អត្តសញ្ញាណដោយ ខៀវ សំផន[92] រួមទាំងការសម្រេចថា "គ្រប់ការរៀបការទាំងអស់ មិនថាការរៀបការនោះ *ត្រូវបានស្នើឡើងដោយបុគ្គល* ឬត្រូវបានផ្គូផ្គងដោយអង្គការក៏ដោយ គឺតម្រូវឲ្យមានការអនុម័តយល់ព្រមដោយអង្គការថ្នាក់ខ្ពស់ជាង"[93]។ ដូច្នេះ គេគ្មានលទ្ធភាពប្រាកដនិយមថា ការដែលបានដាក់កំណត់ហេតុថ្មីនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នឹងនាំឲ្យអង្គជំនុំជម្រះនេះផ្លាស់ប្តូរសាលក្រមឡើយ។

40. ជាចុងក្រោយ ខៀវ សំផន អះអាងទាំងខុសថា ភស្តុតាងក្នុងកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី ទាក់ទងនឹងអវត្តមាននៃការតាមដានក្រោយពេលគាត់ និងប្រពន្ធរបស់គាត់បានរៀបការជាមួយគ្នា

---

[88] *សូមមើល ជាឧទាហរណ៍* ឯកសារ **E1/490.1** ជួន ធី ប្រតិចារឹក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦, 09.11.42-09.13.05 (យោង ថាតើអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងដោយបង្ខំឬទេ៖ "អ្វីដែលខ្ញុំបាននិយាយពីដំបូងគឺថា ខ្ញុំមិនដឹងពីអ្វីដែលបានកើតឡើងនៅអង្គភាពផ្សេងទេ")។

[89] ឯកសារ **F51** សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ៦៣-៦៤។

[90] ឯកសារ **E319/71.2.4** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ:១០៨។

[91] ឯកសារ **E319/71.2.4** កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ:៤៩។

[92] ឯកសារ **F51** សំណុំរឿង ០០៣ សំណើសុំការអនុញ្ញាតឲ្យទទួលយក កថាខណ្ឌ ៦៣ *យោង* ឯកសារ **E465** សំណុំរឿង ០០២/០២ ប្រតិចារឹក កថាខណ្ឌ ៣៥៩៤-៣៥៩៥, ៣៦០២, ៣៦០៨។

[93] *សូមមើល* ឯកសារ **F51** សំណុំរឿង ០០៣ សំណើសុំការអនុញ្ញាតឲ្យទទួលយក សំណុំរឿង ០០៣ កថាខណ្ឌ ៦៣ កំណត់សម្គាល់ជើងទំព័រ ១២២ *យោង* ឯកសារ **E465** សំណុំរឿង ០០២/០២ ប្រតិចារឹក កថាខណ្ឌ ៣៦០២ (សង្កត់ន័យដើម)។

ហៅការសម្រេចរបស់អង្គជំនុំជម្រះ ស្តីពីការរតាមដានទៅលើការរួមដំណេកក្រោយការរៀបការ ថាជារឿងគួរឱ្យសង្ស័យ[94]។ ការសម្រេចមានគុណវុឌ្ឍិរបស់អង្គជំនុំជម្រះសាលាដំបូងថា "ក្រោយពិធីរៀបការរួច គូស្រករដែលត្រូវបានគេតាមដាន*គឺរឿងធម្មតា* ដើម្បីឱ្យប្រាកដថា ពួកគេបានរួមសង្វាសជាមួយគ្នាក្រោយការរៀបការរបស់ពួកគេ"[95]នោះ មិនផ្ទុយនឹងកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី ទេ។ ផ្ទុយទៅវិញ វាអនុញ្ញាតឱ្យមើលឃើញថា មានពេលធម្មតាតិចតួចប៉ុណ្ណោះដែលថាការតាមដានមិនបានកើតឡើង។ ការសម្រេចដែលមានគុណវុឌ្ឍិនេះបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានភាពអនុគ្រោះចំពោះទម្ងន់នៃភស្តុតាង ដោយបានថ្លែងថាការតាមដានបានកើតឡើងមែន ប៉ុន្តែអង្គជំនុំជម្រះក៏មានការគិតគូរទៅលើសេចក្តីសន្និដ្ឋានផ្សេងៗរបស់ភាគីផងដែរ ទាក់ទងទៅនឹងភាពខុសគ្នាៗតាមតំបន់ និងសក្ខីកម្មរបស់សាក្សីដែលថា គ្មានការតាមដានបានកើតឡើង[96]។ ស្រដៀងនេះ សាលក្រមអនុញ្ញាតឱ្យឃើញថា មិនមែនគូស្រករទាំងអស់សុទ្ធតែបានរួមភេទជាមួយគ្នាដោយសារការភ័យខ្លាចការធ្វើទណ្ឌកម្មនោះដែរ[97]។ អង្គជំនុំជម្រះបានផ្តល់គុណវុឌ្ឍិដល់ការសម្រេចរបស់ខ្លួនថា "មានអ្នក*ខ្លះ* បានរួមសង្វាសជាមួយប្តី/ប្រពន្ធរបស់ខ្លួន ដោយសារភ័យខ្លាចមានផលវិបាក ប្រសិនបើពួកគេមិនធ្វើដូច្នេះ"[98]។ ទន្ទឹមនេះ កំណត់ហេតុស្តាប់ចម្លើយថ្មីរបស់ ជួន ធី គឺវាស្របគ្នាទៅនឹងការរកឃើញរបស់អង្គជំនុំជម្រះ ហើយមានលក្ខណៈស្រដៀងនឹងភស្តុតាងដែលបានទទួលយករួចហើយ ដូច្នេះ យើងគ្មានលទ្ធភាពប្រាកដនិយមដែលថា អាចនឹងនាំឱ្យអង្គជំនុំជម្រះផ្លាស់ប្តូរសាលក្រមឡើយ ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយថ្មីនេះត្រូវបានដាក់នៅចំពោះមុខខ្លួន។

## គ. សំណើសុំការអនុញ្ញាតឱ្យទទួលយកភស្តុតាងប្រើភាសាដែលមានលក្ខណៈរំជួលចិត្តខ្លាំង និងពិសពលមិនសមរម្យ

---

[94] ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក, កថាខណ្ឌ ៧១-៧២។

[95] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៦៤៤ *(សង្កត់ន័យដើម)*។

[96] អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញភស្តុតាងពីសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីថា ខុសៗគ្នាទៅតាមតំបន់ដែលមាននៅក្នុងការតាមដានលើការរួមដំណេក និងចំនួនសាក្សីដែលបានប្រកែកថា នេះជាការអនុវត្ត។ *សូមមើល ជាឧទាហរណ៍* ឯកសារ **E457/6/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ("សេចក្តីសន្និដ្ឋានបញ្ចប់របស់ ក.ស.ព"), កថាខណ្ឌ ៥៨៦។ ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២), ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ដែលបានកែប្រែនៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ("សេចក្តីសន្និដ្ឋានបញ្ចប់ដែលបានកែប្រែរបស់ ខៀវ សំផន"), កថាខណ្ឌ ២៣៩២-២៣៩៥។ ឯកសារ **E457/6/3/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ("សេចក្តីសន្និដ្ឋានបញ្ចប់ដែលបានកែប្រែរបស់ នួន ជា"), កថាខណ្ឌ ១១៨០។

[97] *ផ្ទុយនឹងឯកសារ* ឯកសារ **F51** សំណើសុំការអនុញ្ញាតឱ្យទទួលយក, កថាខណ្ឌ ៧១។

[98] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៦៤៦។

41. សហព្រះរាជអាជ្ញាសូមបង្ហាញពីកង្វល់អំពីភាសាដែលមានលក្ខណៈរំជួលចិត្តខ្លាំង និងពិសពលយ៉ាងហោចណាស់ក៏ការនិយាយសំដៅដល់អង្គជំនុំជម្រះសាលាដំបូង ដែលបានប្រើប្រាស់ដោយមេធាវីការពារក្តីនៅក្នុងសំណើសុំឲ្យទទួលយកភ័ស្តុតាង[99]។ និយាយឲ្យចំ សហព្រះរាជអាជ្ញាមានកង្វល់អំពីការចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានពាក់ព័ន្ធនៅក្នុងកំហុសវិជ្ជាជីវៈដែលនាំឲ្យមានភាពអយុត្តិធម៌។ ជាពិសេស ខៀវ សំផន ចោទថា អង្គជំនុំជម្រះសាលាដំបូងបានរារាំងដោយចេតនា មិនឲ្យបើកកិច្ចដំណើរការនីតិវិធីឡើងវិញ បន្ទាប់ពីឯកសារនានាត្រូវបានបង្ហាញ[100] ដែលជាការទប់ស្កាត់មេធាវីការពារក្តីមិនឲ្យ "ពិភាក្សាអំពីខ្លឹមសារនៃកំណត់ហេតុដោះបន្ទុក ឬភាពជឿជាក់បាននៃសាក្សីមួយចំនួនដែលបានផ្តល់សក្ខីកម្មប្រឆាំងនឹង ខៀវ សំផន"[101] ដោយសារតែអង្គជំនុំជម្រះចង់ "កាត់ទោស ខៀវ សំផន ទោះក្នុងតម្លៃណាក៏ដោយ"[102]។ ការចោទប្រកាន់ទាំងអស់នេះមិនត្រឹមតែធ្វើមិនដឹងមិនឮចំពោះកង្វល់របស់អង្គជំនុំជម្រះសាលាដំបូងចំពោះសិទ្ធិរបស់ជនជាប់ចោទ និងកំហុសរបស់មេធាវីការពារក្តី ក្នុងការទទួលយកឧបាស្រ័យដែលបានផ្តល់ជូនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវាយប្រហារទៅលើសុចរិតភាព និងសីលធម៌តុលាការរបស់អង្គជំនុំជម្រះសាលាដំបូងទៀតផង។

42. មេធាវីការពារក្តីក៏បានកំណត់ចរឹកលក្ខណៈនៃការបង្ហាញភស្តុតាងរបស់ ស.ព.អ ក្នុងលក្ខណៈដែលមានការរំជួលចិត្តផងដែរថា "ខ្វះភាពវៀសវវៃយ៉ាងច្បាស់ក្រឡែត"[103]។ ការបង្ហាញភស្តុតាងនោះត្រូវបានធ្វើឡើង "ភ្លាមៗតាមការអនុវត្តដែលអាចធ្វើទៅបាន"[104] នៅពេលដែលបន្ទុកការងារ និងការកំហិតផ្នែកបុគ្គលិកត្រូវបានអនុញ្ញាត៖ ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ គឺវាមានរយៈជាងពីរខែមុនពេលដែលសាលក្រមបានចេញ។ នៅក្នុងអំឡុងនៃរយៈពេលនេះ បុគ្គលិកការិយាល័យអយ្យការទាំងអស់ សុទ្ធតែបានចូលរួមពាក់ព័ន្ធនៅក្នុងការបំពេញឲ្យបាននូវកាលបរិច្ឆេទកំណត់ចុងក្រោយសម្រាប់ការដាក់សេចក្តីសន្និដ្ឋានមានសារៈសំខាន់នៅក្នុងសំណុំរឿង០០២/០២ ព្រមទាំងសំណុំរឿងដ៏សកម្មចំនួនបួនផ្សេងទៀត[105] និងនៅពេលដែលខ្លួនបានបំពេញបាននូវការប្តេជ្ញាចិត្តទាំងអស់នេះ

[99] ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក, កថាខណ្ឌ ១២-១៤។

[100] ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក, កថាខណ្ឌ ១៣-១៤។

[101] ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក, កថាខណ្ឌ ១៣។

[102] ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក, កថាខណ្ឌ ១៤។

[103] ឯកសារ F51 សំណើសុំការអនុញ្ញាតឲ្យទទួលយក, កថាខណ្ឌ ១០។

[104] វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ឯកសារ F2/4/2 សេចក្តីសម្រេចលើសំណើសុំលើកទី៣ របស់ នួន ជា, កថាខណ្ឌ ១៧។

[105] នៅចន្លោះខែមីនា ឆ្នាំ២០១៧ នៅពេលដែលកំណត់ហេតុស្តាប់ចម្លើយនេះអាចឲ្យយើងរកបាន(ជាភាសាខ្មែរ) នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ សាយឡាប ហើយនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ នៅពេលដែល ស.ព.អ បានដាក់បង្ហាញឯកសារទាំងនោះ

ហើយទើប ស.ព.អ អាចធ្វើការពិនិត្យឡើងវិញមានខ្លឹមសារមួយ[106] លើឯកសារចំនួន ៥៧១ ដែលបានប្រមូលសម្រាប់លទ្ធភាពនៃការដាក់បង្ហាញក្នុងសំណុំរឿង០០២/២[107]។

---

ក.ស.ព មិនត្រឹមតែបានគ្រប់គ្រងនៅលើសេចក្តីថ្លែងសម្អាងទៀងទាត់នានានៅក្នុងសំណុំរឿងទាំងអស់ប៉ុណ្ណោះទេ ប៉ុន្តែក៏តម្រូវឲ្យ ១) ធ្វើសេចក្តីព្រាងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ (មានចំនួន ៨០១ទំព័រ - *សូមមើល* ឯកសារ **E457/6/1** សេចក្តីសន្និដ្ឋានបញ្ចប់របស់ ក.ស.ព); ២) ការពិនិត្យឡើងវិញលើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តីក្នុងសំណុំរឿង ០០២/០២ និងការរៀបចំចម្លើយតបរបស់ ក.ស.ព ក្នុងរយៈពេល៩ថ្ងៃ សម្រាប់កិច្ចពិភាក្សាដេញដោលផ្ទាល់មាត់ (សារណារបស់មេធាវីការពារក្តីមានចំនួន ១១១៥ទំព័រ ដោយមិនរាប់បញ្ចូលតារាងមាតិកា - *សូមមើល* ឯកសារ **E457/6/3** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដែលបានកែប្រែរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧, ដែលបានកែប្រែតាមរយៈឯកសារ **E457/6/3/1** សេចក្តីសន្និដ្ឋានបញ្ចប់ដែលបានកែប្រែរបស់ នួន ជា។ ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ដែលបានកែប្រែរបស់ ខៀវ សំផន។ ឯកសារ **E1/520.1** ប្រតិចារឹក, ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/521.1** ប្រតិចារឹក, ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/522.1** ប្រតិចារឹក, ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/523.1** ប្រតិចារឹក, ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/524.1** ប្រតិចារឹក, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/525.1** ប្រតិចារឹក, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/526.1** ប្រតិចារឹក, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/527.1** ប្រតិចារឹក, ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧, ឯកសារ **E1/528.1** ប្រតិចារឹក, ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧)។ ៣) សេចក្តីព្រាងជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់នៃសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/១ (ដោយចាប់ផ្តើមជាមួយនឹងសំណុំរឿង០០៤-ឯកសារ **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សម្អាងហេតុ), ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ និងបញ្ចប់ជាមួយនឹងសំណុំរឿង០០៤/១-ឯកសារ **D308/3/1/19/1.2** សវនាការលើបណ្តឹងឧទ្ធរណ៍, ប្រតិចារឹក, ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧; សំណុំរឿង០០៤/១-ឯកសារ **D308/3/1/19/2.1** សវនាការលើបណ្តឹងឧទ្ធរណ៍, ប្រតិចារឹក, ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧។ ៤) សេចក្តីព្រាងដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង០០៤/២ (មានចំនួន ៥៨៧ទំព័រ ដោយមិនរាប់បញ្ចូលតារាងមាតិកា - *សូមមើល* សំណុំរឿង០០៤/២-ឯកសារ **D351/5** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧; ៥) សេចក្តីព្រាងដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង ០០៣ (មានចំនួន ៩៣៦ទំព័រ ដោយមិនរាប់បញ្ចូលតារាងមាតិកា - *សូមមើល* សំណុំរឿង០០៣-ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ និង ៦) សេចក្តីព្រាងដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង ០០៤ (៧០៤ ទំព័រ ដោយមិនរាប់តារាងមាតិកា - *សូមមើល* សំណុំរឿង ០០៤-ឯកសារ **D378/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ, ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨)។

[106] ស.ព.អ មិនត្រឹមតែបានកំណត់អត្តសញ្ញាណឯកសារពីសាក្សីនានាដែលបានផ្តល់សក្ខីកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានពិនិត្យឡើងវិញយ៉ាងប្រុងប្រយ័ត្នផងដែរទៅលើឯកសារទាំងអស់ ដើម្បីបានព័ត៌មានដោះបន្ទុកជាសក្តានុពល ព្រោះថាបើមិនយកចិត្តទុកវាគឺមិនយុត្តិធម៌។

[107] ឯកសារទាំង៥៧១ រួមមាន ១៣៥ ជាកំណត់ហេតុស្តាប់ចម្លើយ និង៤៣៦ ជាឯកសារភាគីដើមបណ្តឹងរដ្ឋប្បវេណី (ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទម្រង់បែបបទព័ត៌មានបន្ថែម របាយការណ៍អំពីការដាក់ពាក្យសុំ)។

43. ខណៈដែលមេធាវីការពារក្ដីអាចធ្វើអំណះអំណាងយ៉ាងស៊ីប់ស្ទួង អំពីគោលជំហររបស់ពួកគេលើបញ្ហានេះ សារណារបស់ពួកគេត្រូវគិតគូរដល់សេចក្ដីថ្លៃថ្នូររបស់តុលាការ និងភាពអធិកអធមនៃកិច្ចដំណើរការនីតិវិធីនៅចំពោះតុលាការ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ភាសាដែលមានលក្ខណៈធ្វើឱ្យមានការរំជួលចិត្តខ្លាំង និងមានពេលខ្លះ មានលក្ខណៈពិសពសនោះ គឺមិនសមរម្យ និងមិនអាចទទួលយកបានឡើយនៅក្នុងសេចក្ដីថ្លែងសម្អាងនៅចំពោះមុខតុលាការនេះ។ ខណៈមេធាវីការពារក្ដីអាចនឹងត្រូវទទួលទណ្ឌកម្មក៏ដោយ យើងសូមផ្ដល់យោបល់ថា មេធាវីការពារក្ដីគួរតែមានការប្រុងប្រយ័ត្ន ពីព្រោះភាសា និងការចោទប្រកាន់ដូច្នេះ នឹងមិនទទួលបានការត្រាប្រណីឡើយ នៅក្នុងសេចក្ដីថ្លែងសម្អាងនាពេលអនាគត។

## V. ដំណោះស្រាយដែលបានស្នើសុំ

44. តាមសម្អាងហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធសំណើសុំឱ្យទទួលយកភស្តុតាងដែលបានស្នើឡើង និងច្រានចោលសំណើសុំឱ្យទទួលយកភស្តុតាងរបស់ ខៀវ សំផន៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | [signature] |